# មាតិការឿង

ទំព័រ


១. ជីវប្រវត្តិសង្ខេបនៃព្រះគ្រូឈីង-ហាយ ............ ១

២. អាថ៌កំបាំងនៃពិភពលោកខាងមុខ............ ៨

៣. ហេតុអ្វីបានជាអ្នកបរិភោគម្ហូបសាច់(ម្ហូបបួស)............ ៦៨

៤. កិច្ចបញ្ចូបេះ: វិធីក្វាង-យីន............ ៩៥

វិនយ័ប្រាំ............ ៩៧


ឧទ្ទិសនាមសៀវភៅបោះពុម្ពផ្សាយនិងពុទ្ធបរិសទ័
ទាំងឡាយលើពិភពលោកទាំងមូល ។

# ជីវប្រវត្តិសង្ខេបនៃព្រះគ្រូឈីង-ហាយ

ព្រះគ្រូឈីង-ហាយកើតនៅប្រទេស វៀតណាមពុករបស់ព្រះគ្រូជាគ្រូពេទ្យចិនសែមានឈ្មោះល្បីល្បាញ គាត់ចូលចិត្តសិក្សាវប្បធម៌ ពិភពលោកហើយ ជាពិសេសសិក្សាផ្នែកទស្សនៈវិទ្យា ។ ក្នុងចំណោមផ្នែកសិក្សាទាំងនេះដែលគាត់ចូលចិត្តបំផុត គឺក្បួនសិក្សារបស់ព្រះគ្រូឡាវ-តឺនិងត្រាង-តឺ ទុកអោយព្រះគ្រូឈីង-ហាយសិក្សាកាលនៅភាពជាកុមារម្ល៉ះ ។ ព្រះគ្រូឈីង-ហាយបានអានសាច់រឿងអស់នេះ មុនចូលទៅរៀននៅបឋមសិក្សា ។

មិនដូចជាកុមារា-កុមារីសាមញ្ញនោះទេ ព្រះគ្រូឈីង-ហាយពេលណាក៏ដោយ គេឃើញលោកអានក្បួនផ្នែកទស្សនវិជ្ជានិងវប្បធម៌ក្នុងពេលដែលពួកក្មេងៗដទៃទៀតខំធ្វើការណើសិក្សាឬ ប្រឡែងកំសាន្ត ។ នេះហើយដែលធ្វើអោយឪពុកព្រះគ្រូយកចិត្តទុកដាក់ ហើយសួរព្រះគ្រូថាតើកូនយល់មេរៀនអស់ទាំងនេះឬទេ ? ព្រះគ្រូក៏ឆ្លើយថា "បើសិនជាខ្ញុំមិនយល់ខ្ញុំមុខជាមិនអានសៀវភៅនោះទេ "។ ថ្វីបើឪពុកព្រះគ្រូនៅតែយកចិត្តទុកដាក់ក្តី ព្រះគ្រូក៏នៅតែទទួលពិន្ទុយ៉ាងចំណោនជាបន្តបន្ទាប់ ហេតុនេះបានជាឪពុកព្រះគ្រូគាំទ្រកិច្ចការ ចូលចិត្តខុសប្រកតីរបស់ព្រះគ្រូ ។

ថ្វីត្បិតតែឪពុកម្តាយព្រះគ្រូកាន់សាសនាគ្រិស្តក៏ដោយ គាត់ពុំប្រកាន់សាសនាព្រះពុទ្ធ ឡើយជីដូនព្រះគ្រូជាពុទ្ធបរិស័ទ ដែលបង្រៀនទូន្មានព្រះគ្រូអោយតំកល់ ពុទ្ធរូបនិងធ្វើសក្ការៈបូជា។ តាំងពីនោះមកព្រះគ្រូបានពង្រីកកាយវិការរស់រាយមានសុទ្ធាជ្រះថ្លា ដោយមកពីសិក្សាក្បួនព្រះពុទ្ធសាសនា ។ នៅពេលល្ងាចព្រះគ្រូចូលវត្តស្តាប់ធម៌ធម៌ព្រះពុទ្ធពេលព្រឹកត្រឡប់ចូលវិហារីគាត់លិកស្សូត្រធម៌ ពេលព្រឹកចូលទៅស្តាប់សុន្ទរកថា

ប្រៀនប្រដៅពិសិដ្ឋធម៌ ។ នេះហើយដែលធ្វើឱ្យព្រះគ្រូមាន សំនួរផ្លូវចិត្តជាច្រើន ដូចជាមនុស្សយើងកើតមកពីណា ? ចាប់កំណើតកើតជាអ្វីក្រោយពីមរណៈ ? ហេតុអ្វីមនុស្សមានខុសគ្នា ?

មានមួយគ្រានោះនៅមន្ទីពេទ្យខ្ទះវិជ្ជបណ្ឌិត និងគិលានុដ្ឋាក គិលានុដ្ឋាយិការ ព្រះគ្រូចូលមន្ទីពេទ្យជួយជុសលាងអ្នកជំងឺ លាងឆ្នាំងចានបោសសំអាតនិងធ្វើកិច្ចការផ្សេងៗ ដើម្បីសំរួលការឈឺចាប់ របស់អ្នកជំងឺ ។ មិត្តរបស់ព្រះគ្រូនៅប្រទេសខុសៗគ្នាច្រើនតែហៅព្រះគ្រូថាៈ "ព្រះរស់" ឬហៅថា "បុគ្គលកំផ្លែង" ដោយមកពីលោកមានសមានចិត្ត និងធម៌សប្បុរសចំពោះយើទាំងអស់គ្នា។

ព្រះគ្រូមានចិត្តមេត្តាចំពោះសត្វទាំងពួង បើកាលណាមានសត្វឆ្កែ - ឆ្មាឬសត្វដទៃទៀតត្រូវដំណំឬរបួសព្រះគ្រូយកមកផ្ទះថែរក្សាហើយលែងទៅវិញ ។ បើសិនជាព្រះគ្រូឃើញសត្វណាមួយត្រូវគេសំលាប់ ព្រះគ្រូយំហើយរំពឹងគិតថា ធ្វើយ៉ាងណាកុំអោយកើតមានភាពទុក្ខវេទនាបែបនេះក្នុងពិភពលោកយើង ។ ព្រះគ្រូបរិភោគម្ហូបសាបមួយជីវិតហើយខ្លាចបើឃើញគេសំលាប់ជីវិតសត្វធ្វើម្ហូបបរិភោគ ។ កាលនៅជាកុមារីព្រះគ្រូត្រូវបានអ្នកហោរាម្នាក់ថ្លែងថាៈ ព្រះគ្រូជាបុគ្គលមួយរូបមានបញ្ញាឈ្លាសវៃហើយមានចរិយាសម្បត្តិយ៉ាង បណ្ឌិតជាងគេទាំងពួង។ គេទាយ ថាៈ បើសិនព្រះគ្រូនៅម្នាក់ឯង អត់មានគ្រួសារព្រះគ្រូមុខជាបានលុះអរហ័ត្តព្រាសដឹងជាមិនខាន ហើយបើសិនជាមានគ្រួសារវិញ ស្វាមីព្រះគ្រូជាអ្នកមានកិត្តិយសមានកិត្តិស័ពទៀតផង ។ ការទោះទាយនេះកើតឡើងច្រើនលើកច្រើនគ្រាមកដល់សម័យក្រោយៗនេះដែរ ។ ក្នុងពេលដែលព្រះគ្រូឈឹង-

ហាយចាកចេញ ទៅសុំបួសជាភិក្ខុហើយនោះ

មាតារបស់ព្រះគ្រូក៏បានទៅវត្តក្វាង-អ៊ឹម ដើម្បីបន់ស្រន់សុំសេចក្តីណែនាំពីព្រះពុទ្ធជាម្ចាស់ ដែលនៅទីនោះគេនិទានថាអវលោកកិត្តិវរ៉ាពោធិសាត្វាឆ្លើយតបនូវសំនួរទាំងឡាយនៃបរិសទ្ធ័ដោយជ្រះថ្លា ។ មាតារបស់ព្រះគ្រូបានគេជំរាបថា " ព្រះគ្រូជាកុមារីម្នាក់ដែលគេពិបាករកឃើញហើយឆ្នើមជាងគេ គឺមានតែម្នាក់គត់ក្នុងចំនួនកោដិមនុស្សលោក ។ ព្រះគ្រូមកចាប់កំណើតក្នុងលោកនេះ ក្នុងករណីក្វាង-អ៊ឹមគឺដើម្បីសង្គ្រោះមនុស្សសត្វទាំងពួងអោយផុតពីទុក្ខវេទនា " ។

ព្រះគ្រូបានបំរើការមួយរយៈក្នុងឋានៈជាអ្នកបកប្រែ នៅប្រទេសអាឡឺម៉ាញ នៃក្រសួងកាកបាទក្រហមអន្តរជាតិ ។ ព្រះគ្រូបកប្រែភាសាវៀតណាម.បារាំង.អាឡឺម៉ង់.និងអង់គ្លេស ហើយព្រះគ្រូបំរើជនភៀសខ្លួនជាតិវៀតណាម។ ដោយមកពីព្រះគ្រូបំរើការអោយក្រសួងកាកបាតក្រហមបានជាព្រះគ្រូទាក់ទងជាមួយ និងជនជាតិភាសខ្លួនមកពីប្រទេសនានាជាច្រើនហើយព្រះគ្រូបានឃើញជាបន្តបន្ទាប់នូវទុក្ខវេទនា និងគ្រោះថ្នាក់បណ្តាលពីធម្មជាតិ និងសង្គ្រាម ។

ព្រះគ្រូឈីង-ហាយកើតទុក្ខឥតគណនា កាលបើព្រះគ្រូរិះរកវិធីសំរាលការឈឺចាប់ ហើយនិងភាពពិបាកទាំងឡាយដែលមនុស្សលោកឈឺចាប់ដោយមិនអាចបញ្ឈប់បាននោះ។ កិច្ចការអស់ទាំងនេះធ្វើអោយព្រះគ្រូផ្ទេងយល់ចំពោះសតិភ្ញាក់រលឹកយ៉ាងធ្ងន់ទៅទៀតដោយយល់ឃើញថាមានតែវិធីនេះទេដែលអាចសំរាលការឈឺចាប់របស់មនុស្សលោក ។ ហេតុដូច្នោះកាលរស់នៅមច្ឆិមប្រទេស ព្រះអង្គបានប្រកាន់ខ្ជាប់នូវវិធី សមាធិយ៉ាង ម៉ឹងម៉ាត់ហើយរិះរកគ្រូអាចារ្យបាធ្យាយន៍ សិក្សារៀនសូត្រអ្វីៗទាំងអស់ដែលព្រះអង្គអាច

រកបានហើយអនុវត្តនៅវិធីផ្សេងៗទៀតផង ប៉ុន្តែព្រះគ្រូយល់ឃើញថាពុំបានលទ្ធផលអ្វីឡើយ ហើយពុំបានសំរេចនូវភាពភ្ញាក់រលឹកត្រាស់ដឹងអ្វីមួយឡើយ ។ ព្រះគ្រូឈីង-ហាយមានការឆ្ងល់យ៉ាងធំទូលាយខុសប្រក្រតីចំពោះ ទស្សនៈសាសនាទាំងអស់។ ព្រះគ្រូបានសិក្សារៀនសូត្រហើយបង្ហាត់បង្រៀនដំបូន្មាននៃ-ព្រះយេ-ស៊ូ ព្រះពុទ្ធជាម្ចាស់ឡៅ-ស៊ីហើយនិងគ្រូបាធ្យាយដ៏ទៃទៀតនៅរៀងរាល់ពេលព្រះអង្គបានបង្ហាញឱ្យឃើញអំពីភាពដូចៗគ្នានិងសមាធិសាធ្យាយព្រះធម៌គ្រប់បែបយ៉ាងហើយអោយយើងទាំងឡាយឃើញនូវ-ព្រះនេត្រព្រះ -គ្រូភាវនា សច្ចំ ដូចគ្នា ។ ព្រះគ្រូអធិប្បាយជារឿយៗនូវការខ្វែងយោបល់គ្នារវាងសាសនានិមួយៗកើតឡើងនោះ ដោយមកពីការខ្វែងយោបល់រវាងជនម្នាក់ៗនៅប្រទេសផ្សេងៗគ្នា និងកើតឡើងនៅរយៈកាលខុសៗគ្នា ។

ក្នុងរយៈកាលរស់នៅប្រទេសអាឡឺម៉ាញព្រះគ្រូឈើង-ហាយមានសេចក្តីរីករាយ រៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកវិទ្យាសាស្ត្រម្នាក់ជនជាតិអាឡឺម៉ង់។ ស្វាមីព្រះគ្រូមានមហាបរិញ្ញាប័ត្រថ្នាក់បណ្ឌិតលើវិស័យពីរ..... លោកជាស្វាមីម្នាក់មានធម៌សប្បុរស ជួយគាំទ្រដល់ព្រះគ្រូគ្រប់ពេលវេលា លោកក៏ក្លាយទៅជាអ្នកបរិភោគសាបច្រើនតែធ្វើដំណើរជាមួយនឹងព្រះគ្រូក្នុងដំណើរផ្សព្វផ្សាយសាសនា ។ នៅទីបំផុតព្រះគ្រូឈីង-ហាយសំរេចចិត្តត្រូវតែលះលោស្វាមីដើម្បីស្វែងរកផ្លូវត្រាស់ដឹង ។ ព្រះគ្រូបានពិគ្រោះជាមួយព្រះស្វាមីយ៉ាងហ្មត់ចត់ហើយព្រមព្រៀងបែកគ្នាតាំងពីពេលនោះ នេះពិតជាសេចក្តីសំរេចចិត្តមួយដ៏ពិបាកឱ្យអ្នកទាំងពីរ ប៉ុន្តែព្រះគ្រូឆ្ងល់យល់ថាសេចក្តីសំរេចនេះពិតជាត្រឹមត្រូវដើម្បីព្រះគ្រូបន្តនឹងបំពេញគោលដៅអោយបានសំរេច ។ ក្រោយពីពេលលះលោគ្រូសាមកព្រះគ្រូបានរិះរកឃើញវិធីមួយបែបយ៉ាងប្រណីតដែលអាចនាំជនម្នាក់ៗរំ-

ដោះនូវទុក្ខវេទនាក្នុងជាតិនេះបាន ។ នៅនាស៊ីរាំងតម្មាស៊ីត្រា ព្រះពុទ្ធសក្យមុន្នីបានថ្លែងថា: "វិធីក្វាង - យីនជាវិធីមួយបែបខ្ពង់ខ្ពស់ជាងគេក្នុងចំណោមវិធីទាំងឡាយ" ។ នៅពេលនោះពុំមានគ្រូអាចារ្យណាមួយជ្រាបវិធីនេះទេ លុះពេលក្រោយមក ព្រះគ្រូបានធ្វើដំណើរទៅកាន់ភ្នំហិមពាន្ត នៅទីនោះ ព្រះគ្រូបានរកឃើញ លោកគ្រូដ៏ឆ្នើមមួយរូបក្រោយពីបានចំណាយពេលជាច្រើនឆ្នាំមក ។ គ្រូអាចារ្យនេះក៏បានអនុញ្ញាតឱ្យព្រះគ្រូឈិង-ហាយរៀនវិធីក្វាង-យីន ។ ក្រោយពីសង្គ្រំភាវនាមួយរយៈខ្លីមក ព្រះគ្រូបានភ្ញាក់រលឹកទាំងស្រុង ហើយព្រះគ្រូក៏បន្តសង្គ្រំភាវនានៅលើភ្នំហិមពាន្តមួយរយៈ ។

នៅទីបំផុត ព្រះគ្រូវិលមកប្រទេសតៃ-វ៉ាន់ ។ មានសម័យថ្ងៃមួយក្នុងពេលព្រះគ្រូកំពុងសង្គ្រំភាវនាក្នុងអាស្រមខាងក្រោយព្រះវិហារ ក្នុងនាយប់ស្ងាត់មានភ្លៀង និងព្យុះសង្ឃរាបោកបក់ធ្ងូប ពេលនោះស្រាប់តែមានជនមួយក្រុមគោះទ្វារហៅព្រះគ្រូក៏សួរពួកនោះថា: ហេតុអ្វីបានជាពួកគេចូលមកក្នុងពេលពួកគេឆ្លើយថា : យប់? ព្រះពោធិសាត្វក្វាង-យីន (ទេវៈនៃមេត្តាធម៌) បានឆ្លើយតបទៅនឹងការអង្វររបស់យើង ហើយមានពុទ្ធដីកាប្រាប់យើងអំពីព្រះគ្រូថា : ព្រះគ្រូជាមហាអាចារ្យ ដែលយើងទាំងឡាយខិតខំសូត្រធម៌អំពាវនាវឱ្យបានសំរេចនូវផ្លូវកម្មដ្ឋានត្រាស់ដឹង ហើយរំដោះក្នុងជាតិនេះ ។ ព្រះគ្រូបញ្ជាឱ្យអ្នកទាំងនោះចាកចេញ ប៉ុន្តែគេមិនព្រមដើរចេញ ។ ពេលចុងក្រោយមកព្រះគ្រូមានហឫទ័យរំភើប ដោយមកពីអ្នកទាំងនោះមានចិត្តជ្រះថ្លា ព្រះគ្រូក៏ព្រមឱ្យអ្នកទាំងនោះធ្វើសច្ចាប្រណិធានតាំងចិត្តភាវនាពិធីក្វាង-យីន ហើយអ្នកទាំងនោះសំរេចចិត្តចូលបួសបរិភោគម្ហូបសាប ។ ដោយមានការអៀនខ្មាស់ជាធម្មជាតិ ព្រះគ្រូពុំបានរិះរកស៊ីសុភានុសិស្សណាម្នាក់មកបង្ហាត់បង្រៀនឡើយ ព្រះគ្រូមិនដែលទទួលយកសិស្សណាម្នាក់ដើម្បីបំបួសនោះទេ ដូចជានៅ

ប្រទេសឥណ្ឌាដូរអាមេរិក ជាដើម ។ នៅតៃ-វ៉ាន់ ព្រះគ្រូបានត្រូវគេដឹងថា ជាព្រះភិក្ខុណីយជំនើម ដែលគេរុករកឃើញទីពាហើយ ហេតុដូច្នោះព្រះគ្រូពុំអាចជៀសវៀងបានឡើយ ។ តាំងពីនោះមកព្រះគ្រូចាប់ផ្ដើមទេសនាផ្សព្វ-ផ្សាយ ហើយនិងទទួលបំបួសសិស្សទាំងឡាយតាមវិធី ក្វាង-យីន ។ នៅលើកដំបូងមានសិស្សមួយ ក្រុមផ្សាយអំពីបារមីស័ក្តិសិទ្ធិរបស់ព្រះគ្រូ ក្រោយមកមានចំនួនរាប់ពាន់ម៉ឺននាក់ ទទួលសេចក្ដីយល់ព្រមអំពីព្រះគ្រូឱ្យចូលជាកូនចៅ ជាកូនសិស្សច្រើនជាងគេ បំផុតនៅតៃ-វ៉ាន់ ដែលជាទីកន្លែងព្រះគ្រូ ស្ថិតនៅយូរលង់បំផុត ។ ក្នុងប៉ុន្មាន ឆ្នាំថ្មីៗនេះ ព្រះគ្រូបានធ្វើដំណើរទៅប្រទេសនានាផ្សាយវិធីក្វាង-យីន នាទ្វីបអាស៊ី និងពាសពេញសហរដ្ឋអាមេរិក និងនៅអាមេ-រិកឡាទីន ។ ព្រះគ្រូឈីង-ហាយ ព្រះអង្គបានជំនួយជូនដល់បរិស័ទគ្រប់សាសនាទាំងអស់ បានរីកចំរើនខាងផ្លូវចិត្ត តាមវិធីសង្រ្គការនា ថ្វីបើពុំ មានក្រសួងណាមួយផ្សាយ អំពីវិធីក្វាង-យីនក៏ដោយ ក៏នៅគ្រប់កន្លែងលើពិភពលោកសព្វថ្ងៃមានបរិស័ទ ជាច្រើនមានចិត្តចង់ជួយទំនុកបំរុងគ្នា ដើម្បីសិក្សារៀនសូត្រព្រះធម៌នៃ ព្រះគ្រូដ៏ជាទីស្នេហារបស់យើង ។

ព្រះគ្រូបានថ្លែងដំរាបពួកយើងថា: ព្រះអង្គរស់នៅដូចជនសាមញ្ញដែរ ប៉ុន្តែព្រះអង្គបានឆ្លងយល់ច្បាស់អំពីឋានសួគ៌ និងឋានព្រះពុទ្ធរស់នៅ ហើយនិងព្រះអង្គដឹងថា ធ្វើយ៉ាងណាដើម្បីឈានទៅកាន់ទីឋានទាំងនោះ ។ ករណីយរបស់ព្រះអង្គធំចម្បង គឺជួយស្រោចស្រង់យើងឱ្យចាកផុតពីភាពទុក្ខវេទនាភាពជ្រួលច្របល់ក្នុងចិន្ដា ដើម្បីឈានទៅកាន់ភាពយល់ច្បាស់អំពីសេចក្ដីសុខសាន្តនិងសេចក្ដីភ្លឺស្វាងទាំងស្រុង ។ បើសិនជាលោកអ្នកនាងត្រៀមខ្លួនជាស្រេច ហើយព្រះគ្រូនឹងនាំលោកអ្នកចូលមកគេហដ្ឋានជាមិនខាន ។ ព្រះគ្រូទេសនាផ្សាយវិធីក្វាង-យីន ជូនដល់សិស្សទាំងអស់ដោយពុំប្រកាន់ថា ជននោះជាពុទ្ធ

បរិស័ទ ឬជាគ្រិស្តបរិស័ទ ឬជាអ្នកកាន់សាសនាមហាម៉ាត់អ្វីឡើយ ។ ព្រះគ្រូប្រើភាសាអង់គ្លេស-វៀតណាម-ចិន-អាល្លឺម៉ង់-បារាំង សំរាប់ជនណាដែលមានសទ្ធាជ្រះថ្លាចង់សិក្សាធម៌ ដើម្បីជាបរិស័ទពេញលក្ខណៈនោះ សូមអញ្ជើញលេសុំសេចក្ដីអនុញ្ញាត និងស្ដាប់ព្រះធម៌អំពីព្រះគ្រូ ឈីង-ហាយ ដោយឥតបង់ថ្លៃឡើយ ។

# អាថ៌កំបាំងនៃពិភពលោកខាងមុខ

អង្គការសហប្រជាជាតិ, ញ៉ូវយ៉ក

ថ្ងៃ ២៦-៦-១៩៩២

ស្វាគមន៍ព្រះគ្រូឈី-ហាយ មកកាន់អង្គការសហប្រជា-ជាតិ ។ សូមយើងទាំងអស់គ្នាភាវនាមួយសន្ទុះតាម ជំនឿរៀង១ខ្លួនដែលយើងត្រេកអរចំពោះអ្វីដែលយើងមាននូវអ្វីដែលយើងបានផ្តល់ជូន ហើយយើងសង្ឃឹមអ្នកណាដែលពុំទាន់បានទទួលគ្រប់គ្រាន់នោះ សូមឱ្យគេបានទទួលដូចជាយើងដូច្នោះដែរ ជនភៀសខ្លួន លើពិភពលោកអ្នករងគ្រោះដោយសង្គ្រាម ពួកទាហានអស់លោកដឹកនាំអង្គការសហប្រជាជាតិ អ្នកដឹកនាំ រដ្ឋាភិបាល មុខជានឹងសំរេចអ្វីដែលពួកគេចង់ហើយ រួមរស់ដោយសន្តិភាពនោះ ។ យើងមានជំនឿថាអ្វីយើងអំពាវនាវមុខជានឹងបាន ពីព្រោះក្នុងគម្ពីរមានចែងដូច្នោះដែរ ។

សូមអរគុណ! អាត្មាបានមកទីនេះជាយូរមក ហើយមានលោកអ្នកណាបានអញ្ជើញមកទីនេះក្នុងពេលមុនទេ? អាត្មាចង់សំដៅទៅរកលោកអ្នកណា ដែលអញ្ជើញមកស្តាប់ធម៌ទេសនា? ពេលណា? ប៉ុន្មាន? សូមអរគុណ! អស់លោកជ្រាបទេ ចំណងជើងនៃអត្ថបទពេលនេះគឺ "ពិភពលោកខាងមុខ" ពីព្រោះអាត្មាមិនចូលចិត្តទេសនាអំពី " ពិភពលោកបច្ចុប្បន្ននេះទៀតទេ " អស់លោកបានជ្រាបរួចអស់ហើយ ពិតមែនទេ? លោកអ្នកជ្រាបក្នុងពិភពលោកនេះ ក៏ព្រោះតែ យើងមានអង្គការសហប្រជាជាតិ យើងមានសហរដ្ឋអាមេរិក មានទីក្រុងញ៉ូវ-យ៉ក " ផ្លែប៉ោម " តែនៅខាងមុខនៃពិភពលោកនេះ យើងមានរឿងផ្សេង១ច្រើន ខ្ញុំគិតថាអស់លោកដែលមកទី

នេះចង់ដឹងរឿងនេះណាស់ ។ គឺមិនមែនដូច Stephen ទើបតែនឹងបាននិយាយអំពីអច្ឆរិយភាព ឬរឿងរ៉ាវអស្ចារ្យ ដែលអស់លោកមិនអាចជឿបាននោះឡើយ ។ គឺជារឿងរ៉ាវដែលមានលក្ខណៈវិទ្យាសាស្ត្រពិតៗ សមហេតុ សមផល និងសំខាន់បំផុត ។

យើងបានឮអ្វីៗទាំងអស់នោះ ពីគម្ពីរផ្សេងៗគ្នា ដោយពោលថា មានឋានសួគ៌៧ជាន់ ការព្រាស់ដឹងមានច្រើនថ្នាក់ខុសៗគ្នា ។ យើងមានឋានទេវតា មានឋានព្រះពុទ្ធ នៅក្នុងខ្លួនយើងទាំងអស់នេះគឺអ្វីៗដែល សន្មតថាមាននៅក្នុងលោកនេះ ។ ប៉ុន្តែមានចំនួន យ៉ាងតិចតួចសន្មតថា បានទៅដល់គឺមានយ៉ាងតិចណាស់ បើប្រៀបនឹងចំនួនមនុស្សក្នុងពិភពលោកអ្នកដែលមានឋានទេវតានៅក្នុងខ្លួន ឬហៅថា " អ្វីនៅខាង មុខពិភព លោកនេះ " គឺមានចំនួនតិចណាស់ បើសិនមិត្តនៅសហរដ្ឋអាមេរិក មិត្តនឹងបានអានសៀវភៅនិយាយអំពីអ្វីខ្លះមាននៅខាងមុខពិភពលោកនេះ ។ ខ្សែភាពយន្តអាមេរិក-កាំងខ្លះ មិនមែនជារឿងប្រឌិតទាំងអស់ទេ ហើយភាពយន្តរបស់ជប៉ុន ក៏មិនមែនជាប្រលោមលោកប្រឌិតនោះដែរ ។ ពីព្រោះអ្នកខ្លះបានអានសៀវភៅដែលគេសរសេរអត្ថបទអំពីពិភពលោកខាងមុខ ឬមួយពួកគេបានក្រឡេកឃើញឋានទេវតាដែរក៏សឹងមាន ។

ហេតុនោះ ក្នុងឋានទេវតា អ្វីជាការភ្ញាក់ផ្អើលក្នុង ឋានទេព្ដា ? ហេតុអ្វីបានជាយើងអំពល់អំពីឋានទេព្ដា បើយើងមានការងារធ្វើក្នុងលោកនេះ យើងមានការងាររឹងប៉ឹង មានផ្ទះមាំមួន ហើយមានញាតិមិត្តជាទីស្នេហា ។ល។ ពីព្រោះយើងមានវត្ថុអស់ទាំងនេះទៅ ហើយហេតុនោះបានជាយើងយកចិត្តទុកដាក់ដល់ឋានទេព្ដា ។ ឮហាក់ដូចជាមានជំនឿហួសហេតុ ពេលយើងនិយាយដល់ឋានទេព្ដា ។ នោះគ្រាន់ជាការីតព្រាស់ដឹងបង្ករប៉ុណ្ណោះទេ ។ មនុស្ស

ជំនាន់មុននិយាយថា នេះជាឋានសួគ៌តែខាងវិទ្យាសាស្ត្រ យើងអាចនិយាយថាមាន ភាពខុសគ្នារវាងចំណេះដឹងខ្ពស់ផង. សេរីភាពខ្ពស់ផង នេះហើយដែលយើងត្រូវ ដឹង តែថាយើងត្រូវដឹងតាមបែបណា ? ហេតុនោះក្នុងសម័យបន្ទាប់នេះទៅ សហរដ្ឋអាមេរិក យើងទាំងអស់គ្នាបានដឹងអំពីការបង្ក បង្កើនផ្នែកវិទ្យាសាស្ត្រ ថ្មីបំផុត គឺគេមានដល់គ្រឿងម៉ាស៊ីន សំរាប់ជំរុញចូលខ្លួនយើងក្នុងពេលសមាធិ ។ លោកអ្នកបានដឹងឬទេ? អត់ដឹងទេ? ទេ? អត់ទេ? គេលក់នៅសហរដ្ឋអាមេរិកដោយចុះតម្លៃផង ពី៤០០ ដល់៧០០ដុល្លា យោងទៅតាមកំរិតដែលអ្នកចង់បាន ។ ពួកគេហៅ នេះសំរាប់ឱ្យមនុស្សខ្ជិលមិនចង់អង្គុយសង្រ្គំភាវនា ចង់ចូលទៅក្នុងផ្លូវសមាធិតែត្រង់ៗនោះ ។ ឥឡូវនេះ បើអ្នកអត់ដឹងទេ អាត្មាពន្យល់ត្រួសៗជូនជា សណ្ដាប់ ។ ពួកគេនិយាយថា ម៉ាស៊ីនបែបនេះអាចបញ្ចូលឱ្យចូលក្នុងសភាពឈប់សំរាក ខួរក្បាលយើងឋិតនៅក្នុងភាពស្ងប់ស្ងៀម ក្រោយមកអ្នកអាចដើរដល់ភាព បញ្ញាឈ្លាសវៃក្នុងកំរិតខ្ពស់ ផ្ដល់ឱ្យអ្នកមានផ្លូវការចេះ ដឹងខ្ពង់ខ្ពស់ ឈ្លាសវៃ ហើយអ្នកឃើញល្អល្អើយក្នុងខ្លួន ។ ម៉ាស៊ីននេះមានប្រដាប់ថតភ្លេងតន្ត្រី ជ្រើស រើសចំរៀង ហេតុនេះអ្នកត្រូវមានប្រដាប់ពាក់ត្រចៀកច្រកខ្សែអគ្គិសនី ដើម្បីស្រូបជញ្ជាក់អ្នក រួចអ្នកអាចមើលឃើញពន្លឺភ្លើងខ្វះៗ ដូច្នេះអ្នកនឹងត្រូវការប្រើប្រដាប់បិទ ភ្នែក និងប្រដាប់ច្រកត្រចៀក ប្រដាប់ទាំងនោះសំរាប់ឱ្យអ្នកធ្វើសមាធិ ។ ប្រដាប់ទាំងនេះល្អប្រណីតណាស់ តំលៃ ៨០០ដុល្លា ប៉ុណ្ណោះថោកមែនទែន ។ ប៉ុន្តែប្រដាប់សំរាប់ធ្វើភាវនាសមាធិរបស់អាត្មានៅថោកជាងនេះទៅទៀត ឥតបង់ថ្លៃអ្វីទាំងអស់ ហើយប្រើបានរហូត ហើយយើងមិនមិនចាំបាច់បញ្ចូលអគ្គិសនី ឬ ច្រកចូល ដោះចេញ ឬមួយបើម៉ាស៊ីនខូច អ្នកមិនត្រូវ ការជួសជុលអ្វីដែរ ។ ទោះបីក្នុងបច្ចុប្បន្ននេះគេមានភ្លើងអគ្គិសនី និងក្រួងតូរ្យតន្ត្រី ធ្វើដោយមនុស្សលោក ក៏ដោយនេះ

ហើយ ដែលគេត្រូវតែផ្ដល់ជូនឱ្យមនុស្ស លោក ។ ប៉ុន្ដែអាត្មាបានអានអត្ថបទមួយថា អ្វីៗដែលគេត្រូវបំពេញ អាត្មាពុំដែលសោកនៅឡើយ ។ ហេតុនោះបានជាលក់ដាច់ ហើយលក់បានចំនួនច្រើន អាត្មាបានព្យុតនិយាយ ។ ទោះបីប្រដាប់ប្រើប្រាស់ ទាំងនោះនាំទៅកាន់ភាពល់ហើយខួរក្បាល ល្ហែល្ហើយចិត្ត ហើយនិងបង្កើនកិរិតឈ្លាសវៃយ៉ាងណាក្ដី អញ្ចឹងតើអ្នកអាចប្រមើលមើលវត្ថុពិតមានចំនួនប៉ុន្មាន ដែលអាចជួយដល់សេចក្ដីឈ្លាសវៃរបស់យើង? វត្ថុអស់នេះមានលើកិរិតពិភពលោកនេះ តែជនណាក៏ដោយក៏អាចប្រើបានទាំងអស់ យើងទាក់ទងនឹងវត្ថុអស់នេះទេ ។ នេះគឺ ជាតួរ្យតន្ត្រីមាននៅក្នុងឋានសួគ៌ និងស្គរសំឡេងនៅខាងក្នុងឋានសួគ៌ ។ យើងអាចជំរុញ និងបង្កើនសំឡេងតូរ្យតន្ត្រីធំតូចនៅក្នុងខ្លួនយើង ឱ្យផុតពីពិភពលោកនេះដោយខ្លួនឯង ហើយអាចឈានទៅដល់កិរិតយល់ឃើញជ្រៅជ្រះជាងនេះទៀតផង ។

អាត្មាប៉ាន់ស្មានទៅ គឺដូចជាក្បួនច្បាប់រូបសាស្ត្រដូច្នេះដែរ ។ អ្នកចង់បាញ់កាំជ្រួចឱ្យរត់ផុតពីទំនាញព្រះធរណី គឺអ្នកត្រូវជំរុញពីក្រោយ ហើយបើវា (ហោះរហ័សនោះ) ពន្លឺភ្លើងក៏បញ្ចេញមកផងដែរ ។ បើសិនយើងដើរលឿនទៅមុខ មុខជាយើង ........... និយាយដូចម្ដេច ........... អាត្មានិយាយភាសាចិនច្រើនពេក ។ យើងអាចប៉ក្ខី ហើយយើងអាចព្យុសំឡេង ។ ស្គរសំឡេងត្បូររញ្ជួយម្យ៉ាងដែលជំរុញយើងឡើងទៅ ដល់កិរិតខ្ពស់ តែក្នុងចិត្តមានភាពស្ងប់ស្ងៀម ឥតមានបញ្ហាច្រើនប៉ុន្មានឥតបង់ថ្លៃ ហើយឥតអំពល់ដល់ការដកពិសោធន៍របស់យើងផង ។ នោះគឺផ្លូវសំរាប់យើង ឈានទៅមុខ ។ អ្វីដែលថិតនៅលោកខាងមុខ គឺ គ្រាន់បើជាងអ្វីៗក្នុងលោកយើងនេះ អ្វីៗទាំងអស់ដែលយើងអាចប៉ាន់ស្មាន និងមិនអាចប៉ាន់ស្មានបាន ។

បើមានគួរពិសោធន៍ពីមុន ក្រោយមកយើងអាចដឹងដែរ ។ ពុំមានជនណាម្នាក់និយាយប្រាប់យើង ពីការពិតឡើយ ។ ប៉ុន្ដែយើងត្រូវតែព្យាយាម

ប្រព្រឹត្តរៀងជាប ហើយយើងត្រូវមានចិត្តស្មោះសជ្រះថា បើពុំនោះសោតទេ គ្មាននរណាមួយអាចធ្វើជំនួសយើងបាន ទេ ។ ហើយក៏ដូចជាគ្មាននរណាផ្សេងទៀតអាចជំនួសការងារក្នុងការិយាល័យសហប្រជាជាតិ ហើយអ្នកបើកប្រាក់ខែប្រចាំនោះ ។ មិនខុសអ្វីពីគ្មាននរណាមួយ ជួយទទួលទានបាយជំនួសយើង ហើយអ្នកឃើញឆ្អែតទៅវិញនោះទេ ហេតុនេះមានតែផ្លូវម្យ៉ាងគឺជាកពិសោធន៍ ។ យើងត្រូវស្ដាប់អ្នកមានបទពិសោធន៍ និយាយប្រាប់យើង ប៉ុន្តែយើងមិនត្រូវទទួលយកបទពិសោធន៍នោះច្រើនហួស ពេកទេ ។ យើងអាចមានការពិសោធន៍មួយពេល ឬ មួយពីរបីពេល ឬពីរបីថ្ងៃតាមតែថាមពល នៃជនដែលជាអ្នកមានបទពិសោធន៍ ។ ក្រោយមកយើងមុខតែឃើញពន្លឺខ្លះៗ ឬឮសំឡេងខ្លះដោយមិនចំបាច់ខំប្រឹងឡើយ តែភាគច្រើនមិនអាចពន្យារពេលបានយូរឡើយ ។ ហេតុនោះ យើងត្រូវធ្វើការពិសោធន៍ដោយខ្លួនឯងផ្ទាល់ ។

នៅខាងមុខនោះ មានពិភពលោកជាច្រើនខុសៗគ្នា ។ យើងអាចយកឧទាហរណ៍ ដូចជាមានពិភពលោកមួយតូចខ្ពស់ជាងនេះបន្តិច ។ អ្វីដែលយើងហៅថា ពិភពលោកមានរូបភាពភ្លឺចិញ្ចែងតាមទាមស័ព្ទ នៃបច្ចឹមប្រទេស ។ នៅពិភពលោកប្រភេទនេះ គេមានរាប់រយឋានខុសៗគ្នា នៅឋាននីមួយៗមានពិភព លោករៀងៗគ្នា ហើយជានិមិត្តរូបនៃការយល់ឃើញ រាល់គ្នាមិនខុសអ្វី យើងចូលមហាវិទ្យាល័យ ថ្នាក់នីមួយៗ មានកិរិតចេះដឹង និងយល់ឃើញខុសៗគ្នាដូច្នោះដែរ ហើយឃើញមានភាព ស័ក្តិសិទ្ធិច្រើនប្រភេទហើយ យើងក៏ចូលទៅក្នុងភាពអស់ទាំងនេះដែរ ។ យើងអាចព្យាបាលអ្នកជម្ងឺយើងអាច--មានពេលយើងអាចមើលឃើញនូវអ្វីៗ ដែលអ្នកដទៃមិនអាចមើលឃើញឡើយ។ យើងមានយ៉ាងតិចបំផុត ចំនួន៦ប្រភេទស័ក្តិសិទ្ធិខុសគ្នា ។

យើងអាចមើលឃើញផុតពីព្រំដែន ចម្ងាយយើងអាចឮសូរសំឡេងហួសកំរិត ។ ចំងាយពីកន្លែងនិមួយៗមិនជាបញ្ហាអ្វីឡើយ ។ ហេតុនេះបានជាគេហៅថា ត្រចៀកទិព្វ "ឋានសួគ៌" ឬ ភ្នែកទិព្វ "ឋានសួគ៌" យើងអាចមើលឃើញចុះជនម្នាក់ៗ យើងមើលឃើញគេចង់អ្វី មានគំនិតអ្វីជួនកាលយើងអាចមើលឃើញ ។ល។ នេះជាថាមពល ដែលយើងមាន ដោយយើងបានឈានទៅដល់កំរិតទី១ នៃឋានទេព្តា ។ នៅ ឋានទី១ ដូចអាត្មាបានជំរាបមកពីទីនោះមានកំរិតជាច្រើនខុសគ្នា ដោយមិនអាច រាយរាប់ជាសំដីបានឡើយ ។

កាលបើយើងទៅដល់នោះ រួចយើងធ្វើសង្រ្គាមនាមុខជាយើងនឹងមានសមត្ថភាពជាច្រើនថែមទៀត ។ ក្រោយមកយើងនឹងពង្រីកនូវបញ្ញាឈ្លាសវៃខាងវប្បធម៌ដែលមិនធ្លាប់មានពីមុនមក ។ យើងបានដឹងបានស្គាល់អ្វីៗច្រើនជាងអ្នកដទៃ មានរបស់របរជាច្រើនជូនឱ្យយើងហាក់ដូចជាធ្លាក់មកពីស្ថានសួគ៌ ជួនកាលជូនជារបរ រកស៊ីជួនបញ្ហារៀងវៃផ្នែកអាជីវកម្ម ជួនជាលុយកាក់និងវត្ថុផ្សេងទៀតផង ។ យើងចាប់ផ្តើមសរសេរកំណាព្យ គូរគំនូរ ឬអាចធ្វើអ្វីមួយដែលមិនអាចធ្វើកាលពីមុន ហើយយើងមិនអាចគិតថា យើងអាចធ្វើការអស់ទាំងនោះបានទៀតផង ។ នោះជាឋាននៅកំរិតទី១ ហើយយើងអាចសរសេរកំណាព្យ សរសេរសៀវភៅយ៉ាងល្អប្រណិតផង ។ ឧបមាថា ពីមុនមកយើងពុំមែនជាអ្នកនិពន្ធជំនាញ តែឥឡូវនេះយើងអាចសរសេរសៀវភៅបានទៅវិញ ។ នេះក៏ជាផលកំរៃសំភារៈយើងបានទទួល នៅឯកំរិតឋានទី១ ។ តាមពិតទៅវិញវត្ថុទាំងនេះពុំ មែនជាជំនួយរបស់ទេព្តាឡើយ ។

បណ្តាវត្ថុអស់ទាំងនេះ ស្ថិតនៅក្នុងខ្លួនយើង ពីព្រោះយើងបានដាស់វាឡើង ហេតុនេះវានៅមានជីវិត ម្ល៉ោះហើយយើងអាចយកប្រើការបាននេះ ហើយជាពតិមានមកពីឋានកំរិតទី១ តើស្រួលទេ ? លោកអ្នកចង់ស្គាល់ ទៀតទេ

ចាំ ! មិនថីទេ ! លោកអ្នកមានដែល ពួម្តងណាទេ ឮរួចហើយ អ្នកណា និយាយ? អីចឹងអាំ ! តើលោកនោះមាននិយាយអ្វីក្រៅពីនោះទេ? អីចឹងបាន ណាំ ! ។ ឥឡូវនេះយើងឡើងទៅឋានខ្ពស់បន្តិច និយាយឧបមា រួចយើងឃើញវត្ថុ និងទេសភាពច្រើន ហើយយើងបានឈោងទៅកាន់វត្ថុ ច្រើនដទៃឯទៀត ។ អាត្មាពុំអាចនិយាយប្រាប់លោក អ្នកនូវរឿងទាំងនេះបាន ទេតាមការពិត ។ ចាំ ! ដោយយើងអត់មានឱកាសគ្រប់គ្រាន់ ។ ម្យ៉ាង វិញទៀតយើងត្រូវការស្តាប់វត្ថុដ៏ល្អប្រណិត គឺនំនិងគ្រាប់ស្ករ យើងពុំទាន់បានញ៉ាំ នោះ ហេតុនេះអាត្មាគ្រាន់តែក្រេបយកឱជារសប៉ុណ្ណឹង ។ បើលោកអ្នកចង់ ញ៉ាំនឹងហើយផ្សេងទៅវិញ យើងចែកជូនម្ហូបអាហារពិត១ចា !. បើលោកអ្នកចង់ ញ៉ាំមែនទែននោះ ។

ឥឡូវនេះយើងដើរឡើងទៅមួយកំរិតគឺឋានទី២ កន្លែងយើង ហៅថា ទី២ នេះគ្រាន់តែសំរួលរឿងរ៉ាវប៉ុណ្ណោះឯង ។ នៅឋានទី២ យើងក៏អាចមាន សមត្ថភាពច្រើនជាងឋានទី១ រួមមានទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយផង ។ ប៉ុន្តែការសំរេចជាងគេបំផុតទៅឋានទី២ នេះគឺយើង មានសមត្ថភាពនឹងទៅឆ្លង-ឆ្លើយកិច្ចការនិមួយ១ ។

ហាក់ដូចជាគ្មាននរណាមួយអាចរឹបយកជនមួយរូប ដែលគេបានសំរេច ទៅឋានកំរិតទី២នោះ ព្រោះគេមានរិទ្ធិអំណាចខាងវោហារ វាចា ហើយសោភ័ណ្ឌ ភាពវៀងវៃនេះ គឺចិត្តនៅក្នុងរិទ្ធិអំណាចនេះឯង ។ ចំនួនមនុស្សភាគច្រើន ដែលមានបញ្ញាធម្មតា ឬអៃ-ក្យូធម្មតានោះ មិនអាចទទឹមបាននឹងជននេះ ព្រោះ កំរិតឈ្លាសវៃរបស់គេឡើងខ្ពស់ទៅហើយ ។ មិនត្រឹមតែយើងមានខួរក្បាល ធម្មតានោះឡើយ យើងនៅមានខួរក្បាលទិព្វ ខួរក្បាលនៅឋានសួគ៌ ភាពឈ្លាស វៃមាននៅក្នុងខ្លួនយើង ។ ឥឡូវនេះចាប់ផ្តើមបើកចំហរ ។ នៅប្រទេស

ឥឡូវ គេហៅឋាននេះថា "ពោធិ" មានន័យថា គំនិតឈ្លាសវៃ ហើយបើយើងសំរេចដឹងនូវ "ពោធិ" យើងប្រែទៅជាព្រះពុទ្ធ ។ ហេតុនោះពាក្យថាពុទ្ធមកពី "ពោធិ" ហើយនិងពុទ្ធា ។ ឥឡូវនេះព្រះពុទ្ធមានន័យច្បាស់លាស់បែបនោះ ។ ពុំទាន់ចប់ឡើយ មិនត្រឹមតែអាត្មាឱ្យសនាមលោកអ្នកដល់ព្រះពុទ្ធប៉ុណ្ណោះទេ នៅមានច្រើនជាងនោះទៀត ។ ហេតុនេះបានជាភាគច្រើន គេហៅអ្នកបានត្រាស់ដឹងថា ជាព្រះពុទ្ធ បើសិនជាព្រះអង្គពុំស្គាល់ឋានផុតពីគំនិតឋានទី២នោះ ច្បាស់ជាព្រះអង្គសព្វព្រះទ័យណាស់ ។ ចាំ ! ដោយមកពីព្រះអង្គជាព្រះរស់ ហើយកូនសិស្សមុខជាហៅ ព្រះអង្គជាព្រះពុទ្ធ ។ ប៉ុន្តែតាមការពិតវិញ បើសិន ព្រះអង្គគ្រាន់តែដើរដល់ឋានគំនិតទី២ ព្រះអង្គអាចមើលឃើញផ្ទះមនុស្សម្នាក់ៗ ពីអតីតរហូតដល់បច្ចុប្បន្ន រហូតដល់អនាគត ហើយព្រះអង្គមានព្រះវោហារវាចា យ៉ាងពេញលេញនោះពុំទាន់ឱ្យឈ្មោះថាជាទីបញ្ចប់របស់ឋាននៃមេត្តាឡើយ ។ ហើយក៏ពុំមានជនណាមួយគួរពេញចិត្តនឹងសមត្ថភាពហាត់អានអក្សរ ក្នុងអតីតកាល ក្នុងបច្ចុប្បន្ន ឬទៅអនាគតពីព្រោះនេះជាជំពូក សំណុំរឿងមួយតាមនាមស័ព្ទនៅប៉ែកអឺរ៉ុបគេច្រើនប្រើអស់លោកអ្នកប្រតិបត្តិយូ-គ្នា ឬសង្គ្រាវនាមុខជានឹង យល់អំពីសំណុំរឿងនេះ ។ នេះជាបណ្ណាល័យម៉្យាង នៅជិតទីស្នាក់ការអង្គការសហប្រជាជាតិ ។ លោកអ្នកដឹងទេក្នុងនោះមាន គ្រប់ភាសាទាំងអស់ លោកអ្នកដឹងទេមានអ្វីកើតឡើងនៅប្រទេសនោះ ។ យល់ទេ? ដូចគ្នានឹងអ្នកដែលទៅដល់ឋាទី២ គេនឹងយល់អាចបកស្រាយនូវគំរូនៃជនម្នាក់យ៉ាងច្បាស់លាស់នូវអ្វីៗអ្នក ឃើញផ្ទាល់ខ្លួនរបស់អ្នក។ នៅមានអ្វីៗច្រើនទៀត ដែលយើងមានមកពីឋានទី២ ។ ប៉ុន្តែកាលបើអ្នកឡើងទៅកាន់ឋានទី២ ហើយអ្នកនឹងឃើញចាប់ចិត្ត គឺពិតជាព្រះរស់ ព្រោះអ្នកបានយល់អំពី "ពោធិ" មានបញ្ញាវៀងវៃ ។ យើងបានដឹងយ៉ាងច្រើនទៀតចំនួនដែលយើងមិនអាចស្គាល់ពេញោះ ហើយនូវអ្វីដែល គេហៅថាស័ក្តិសិទ្ធិនោះ

មុខជាកើតមានដល់យើង ទោះបីយើងចង់ ឬមួយពុំចង់ ព្រោះសញ្ញារបស់យើងបានតោងជាប់ជាមួយនឹងឋានខ្ពស់ នៅឋានដែលមានធនធានព្យាបាលរោគ មានរបៀបរៀបចំជាស្រេចធ្វើឱ្យ ឆាកជីវិតយើងចិត្តទៅហូរហែរ ហើយធូរគ្រាន់បើផង ។ បញ្ញាឈ្លាសវៃរបស់យើង ឬ "ពោធិ" បានបើកចំហឱ្យយើងរុករកបណ្តាពតិមានក្នុងអតីតកាល ក្នុងបច្ចុប្បន្ន ដើម្បីរៀបចំមកវិញនូវឆាកជីវិតរបស់ដែល ឆាកជីវិតរបស់ដែលយើង ធ្វើទោសកំហុសពីជាតិមុនមកនោះ លោកអ្នកយល់ ឬទេ? ហេតុនោះបណ្តាលឱ្យ យើងចេះកែប្រែទោសកំហុស ក្រោយមកយើងនឹងមាន ការរស់នៅម្យ៉ាងដោយសុខសាន្តល្អប្រសើរ ។ ឧបមាថា បើយើងមិនដឹងនូវអ្វីមួយ ដែលយើងបំពានទៅលើអ្នកជិតខាង ដោយមកអំពីអំពើម្យ៉ាង បណ្តាលឡើងដោយអចេតនា ឥឡូវនេះយើងដឹង ។ លោកអ្នកយល់ឬទេ? ងាយយល់ណាស់! បើសិនជាយើងមិនដឹងអ្នកជិតខាង យើងរករឿងឆាឆៅដោយស្ងាត់ៗ ហើយគេរិះរកមធ្យោបាយធ្វើបាបយើង ព្រោះមកពីការភ័ន្តច្រឡំម្យ៉ាង ឬដោយមកពីយើងមានធ្វើបាប អ្វីម្យ៉ាងទៅលើគេ ។ តែឥឡូវនេះយើងដឹងហេតុម្តេចកកើត ហេតុនោះ ។ ហេតុនេះងាយទេ យើងអាចទៅសុំទោស ឬនិយាយទូរស័ព្ទ ឬធ្វើពិធីជប់លៀង ហើយ អញ្ជើញគេមកលុប-លាងការភ័ន្តច្រឡំនោះ ។ មិនខុសអ្វីពីការយើងឡើងដល់កំរិតឈ្លាសវៃ យើងយល់នូវអ្វីៗទាំងអស់ រួចរៀបចំខ្លួនដោយស្ងប់ស្ងៀម ដើម្បីទាក់ទងនឹងប្រភពពតិមានស័ក្តិសិទ្ធិ ដែលអាចជួយយើង មានជីវភាពរស់នៅហូរហែល្អប្រសើរ ។ យើងគប្បីបន្ថយជំទាបបំផុតនូវចំនួនគ្រោះថ្នាក់ នូវបណ្តាស្ថានភាព និងលក្ខន្តិកៈមិនល្អក្នុងការរស់នៅនៃផងយើង ។ យល់ ឬទេ ? ចាំ ! ចាំ ! ហេតុដូច្នោះក្នុងពេល យើងឡើងដល់ឋានកំរិតទី២ កន្លែងនេះហើយគួរជាទីគាប់ចិត្ត ។

ព្រោះហេតុនោះ អ្វីៗអាត្មាបានពន្យល់ជូន លោកអ្នកសុទ្ធសឹងតែផ្នែកវិទ្យាសាស្ត្រ

ពិតជាត្រឹមត្រូវ ហើយមិនចាំបាច់យល់ថានោះជាអ្នកភាវនាតាម "យ៉-គ្គី" ឬអ្នកសង្រ្គំភាវនាឯទៀត ជាជនមួយប្រភេទវិសេសវិសាលជាងអ្នកសាមញ្ញ ។ ពួកគេជាមនុស្សសាមញ្ញ ដូចយើងទាំងអស់គ្នាគេភ្ញាក់រលឹកដោយមកពីគេដឹងថា ត្រូវធ្វើរបៀបណាទៅសហរដ្ឋអាមេរិកគេនិយាយថាអ្វីៗ ធ្វើទៅតាមការប៉ុនប្រសប់ ហើយយើងអាចធ្វើបានកិច្ចការគ្រប់ជំពូក ។ ពិតអញ្ចឹងយើងអាចរៀនគ្រប់មុខទាំងអស់នេះជាជំពូកដើរហួសពីពិភពលោកវិទ្យាសាស្ត្រយើងក៏អាចរៀនបានដែរ ។ ពុហាក់ដូចជាប្លែកណាស់ អ្វីៗមានភាពខ្ពស់ ពិតជាវាមានភាពធម្មតាដែរ ។ ងាយជាងយើងរៀននៅវិទ្យាល័យនោះទៀត នៅទីនោះមានមេរៀនពិបាកៗដូចជាក្បួននិពន្ធ និងចំណោទជាដើមឋានក៏រិតទី២ ឋានក៏រិតទី២ ឋានក៏រិតច្រើនខុសៗគ្នា អាត្មាចង់និយាយសង្ខេប ដោយមិនអាចរៀបរាប់ ពិស្តារនូវអាថិកំបាំងនៃឋាននោះ។ ចាំ ! យ៉ាងណាមិញ លោកអ្នកមុខជាឃើញទីកន្លែងនោះក្នុងពេលធ្វើដំណើរ ជាមួយនឹងព្រះគ្រូរបស់លោកអ្នក ។ ហេតុនេះ ពុំមានជាអ្វីអាថិកំបាំងនោះទេ -- តែវែងអន្លាយ លោកអ្នកដឹងទេ បើយើងត្រូវឈប់ផ្អាកនៅឋាននិមួយៗ ក្នុងឋាននិមួយៗមានក៏រិតជាច្រើន ក៏រិតខ្ពស់-ក៏រិតទាប ហើយយើងត្រូវឈប់ធ្វើការជកពិសោធន៍នូវអ្វីៗទាំងអស់ ហេតុនេះត្រូវប្រើពេលយូរ ។ ហេតុនេះជូនកាលព្រះ គ្រូនាំលោកអ្នកទៅកាន់ឋានមួយយ៉ាងឆាប់រហ័ស ។ ចាំ !

ចាំ ! ចាំ ! ពីព្រោះយើងឥតមានត្រូវការចង់ រៀនធ្វើគ្រូ យើងមិនត្រូវការរៀនអ្វីច្រើននោះទេ ឈឺក្បាលតើ! ។ ហេតុនោះអាត្មានាំលោកអ្នកធ្វើដំណើរចេញទៅហើយដល់មកផ្ទះ តែប៉ុណ្ណឹងក៏ឃឹតឃូរណាស់ដែរ ។ ជួនកាលត្រូវប្រើពេលអស់មួយជីវិត ប៉ុន្តែភាពត្រាស់ដឹងវិញបានជាបន្ទាន់បានទាន់ចិត្ត ។ តែគ្រាន់ជាកិច្ចចុះឈ្មោះចាប់ផ្តើម លោកអ្នកដឹងទេ ? ថ្ងៃដំបូងលោកអ្នកចុះឈ្មោះរៀនមហាវិទ្យាល័យ លោកអ្នក ទៅជានិសិត្សមហាវិទ្យាទៅហើយ ។ ប៉ុន្តែពុំមែន រៀនទាក់ទិននឹងបរិញ្ញាប័ត្រផ្នែកវេជ្ជបណ្ឌិតនោះទេ ។ គឺរៀនទ៤-៦ ឬ១២ឆ្នាំចេញពីសាលា ។ លោកអ្នក ទៅជានិសិត្សមហាវិទ្យាល័យ បើសិនជាលោកអ្នកចុះឈ្មោះរៀននៅវិទ្យាល័យមែនអញ្ចឹងទេ? ហេតុនេះអ្នកទាំងពីរត្រូវសហការជាមួយគ្នា ។ មិនខុសអ្វីបើយើង ដើរផុតពីសកលលោកនេះទេ និយាយឧបមាអាត្មាគ្រាន់ តែនិយាយកំប្លែង ពីព្រោះនៅញ៉ូវ-យ៉ក ឥតមានក្លែងណាទៅទៀត ។ យើងបានស្គាល់អស់ម៉ែនហែតតឹន ឡុងបិច ស្ទូតបិច និងឆ្នេរសមុទ្រទាំងអស់ ឧបមាថា យើងចង់ទៅលើឋាន មួយពិសេសមើលតើនៅទីនោះមានអ្វីប្លែក? បានឬទេ? ម្តេចមិនបាន ព្រោះយើងចាយលុយច្រើន ដើម្បីទៅក្រុងមៃយ៉ាមី ភើឡូរីដា គ្រាន់តែងូតទឹកកំសាន្ត ម្តេចបានជាយើងមិនអាចទៅពិភពលោកផ្សេង ទៅមើលប្រភពជិតខាងយ៉ាងដូចម្តេចទៅ? មនុស្សទីនោះ

សងតំលៃចរាចរខ្លួនឯងបែប ណេក? អាត្មាយល់ថាពុំមានអ្វីប្លែកឡើយ ។ ទេ? នោះគឺជាប្រភេទធ្វើដំណើរដោយព្រលឹង ដោយវិញ្ញាណ មិនមែនដោយខ្លួនយើងទេ ។ មានប្រភេទពីរក្នុងការធ្វើដំណើរ ។ ហេតុនោះត្រឹមត្រូវហើយងាយយល់ណាស់ ។ ឥឡូវនេះ យើងនៅឋានក្នុងឋានកំរិតទី២ អាត្មានិយាយអ្វីទៀត ។ ហ្នឹងហើយបានថា យើងបន្តដំណើរក្នុងឋាននេះ តែក្រោយមក យើងអាចស្គាល់ពិភពលោកដទៃ ក្នុងពេលជាមួយនេះដែរ ។ លោកអ្នកយល់ឬទេ? ពីព្រោះយើងធ្វើដំណើរមិនខុសអ្វីលោកអ្នកជាជាតិ អាមេរិកាំង ឬជាតិណាមួយដទៃ ចង់ធ្វើដំណើរទេស-ចរណ៍ឱ្យស្គាល់ ប្រទេសជិតខាងយើងបែបណាទៅ? ហើយអាត្មាស្មានថា ភាគច្រើនអស់លោកបំរើការក្នុងសហប្រជាជាតិនេះពុំមែនជាកំណើតអាមេរិកាំងឡើយ ។ ពុំមែនទេ----មែន ---- លោកអ្នកដឹងពុំមានអ្វីប្លែក គឺដូចគ្នា ។ យើងអាចធ្វើដំណើរទៅខាងឋានដទៃ ឬទៅឋានក្បែរដើម្បីរុករកមើល ។ ពីព្រោះនៅឆ្ងាយយើងមិនអាចដើរបាន យើងពុំអាចជិះរ៉ុក-កែត ហើយក៏ពុំអាចជិះ យូ-ហ្វូរ៍ បានដែរ ។ មានពិភពលោកខ្លះឋិតនៅឆ្ងាយ យូ-ហ្វូរ៍មិន អាចហោះដល់ផង យូ-ហ្វូរ៍ ជាវត្ថុប្រដាប់គ្រឿងម៉ាស៊ីនទំនើប ដោយមិនស្គាល់ឈ្មោះអាចហោះយ៉ាងលឿនបំផុត ។ ឥឡូវយើងមានប្រដាប់ម្យ៉ាងនៅក្នុងខ្លួនអាចហោះរហ័សជាងយូ-ហ្វូរ៍ ទៅទៀត គឺព្រលឹងរបស់យើង ។ ជួនកាលយើង ហៅថាវិញ្ញាណ យើងអាចហោះដោយមិនចាំបាច់ប្រើប្រេងសាំង មិនត្រូវការក្រុមនគរបាល ឬមិនខ្លាច ឧបសគ្គចរាចរអ្វីៗទាំងអស់ ។ ហើយមិនខ្លាចថ្លៃណា អារ៉ាប់មិនលក់ប្រេងសាំងឱ្យនោះដែរ ពីព្រោះខ្លួនទី ពឹងខ្លួន ។ មិនខ្លាចខូចផង ខ្លាចតែយើងធ្វើឱ្យ ហិនហោចដោយ

សារវន្តបំពានក្រិត្យវិន័យរបស់ធម្មជាតិប៉ុណ្ណោះ បំពានបរិយាកាសល្អប្រណិតនៃឋានសួគ៌ និង ឋានមនុស្សលោក ។ យើងប្រាប់អ្នកដឹង បើអ្នកដឹង នោះ ។ អាត្មាពន្យល់ត្រួសៗ អាត្មាពុំមែនជាអា-ចារ្យទេកុំបារម្ភអ្វី អាត្មាមិននាំលោកអ្នកទៅព្រះវិហារទេ នេះគ្រាន់តែជាឧបមាប៉ុណ្ណោះ ។ មានក្រិត្យវិន័យខ្លះៗនៅលើពិភពលោក យើងមិនខុសអីពេលយើង បើកឡាន យើងត្រូវចេះវិន័យ និងចាំក្បួនចរាចរ ។ ចង្កៀងក្រហមត្រូវឈប់ ចង្កៀង ខៀវត្រូវទៅ ។ បើកបរខាងស្តាំនៅលើមហាវិថីត្រូវ ដឹងល្បឿនប៉ុន្មាន? នេះជាឧបមាខ្លះៗធម្មតានៅលើពិភពលោកនេះ លោកអ្នកយល់ទេ? ពិភពលោកខាងលើទៀតឥតមានក្រិត្យវិន័យទេ? យើងសេរី ជាពលរដ្ឋមានសិទ្ធិសេរីភាព ប៉ុន្តែយើងត្រូវធ្វើយ៉ាងណាដើម្បីឱ្យទៅជាសេរីនោះ ។ បើកាលណា យើងរស់នៅលើពិភពលោកនេះយើងត្រូវតែគោរពក្បួនច្បាប់ច្រើនកាលណារឹតតែពិសេស ដើម្បីជៀសផុតពីបញ្ហាកើតហេតុ ។ ហើយរថយន្តយើងនៅល្អ ម៉ាស៊ីនពូកែយើងអាចបើកបរបានរហ័សឥតមានអ្វីឡើយ ។ ហេតុនេះ ក្បួនវិន័យនេះបានត្រូវគេចងក្រងឡើងក្នុងគម្ពីរ ក្នុងគម្ពីរគ្រិស្តសាសនា គម្ពីរព្រះពុទ្ធសាសនា គម្ពីរព្រះហិរន្តូរ ។ គឺជាគម្ពីរធម្មតាដូចជាទូន្មានយើង កុំធ្វើបាបអ្នកជិតខាង កុំសំលាប់ជីវិតគេ កុំបំពានឳ្យអ្វីៗម្យ៉ាង លោកអ្នកដឹងឬ? ចេះរាប់រក ស្រឡាញ់គ្នា កុំលួចប្លន់ជាដើមហើយកុំទទួលទានសុរា រួមមានគ្រឿង ឱសថស្រវឹងសព្វថ្ងៃ ។ ប្រហែលជាព្រះពុទ្ធជាអម្ចាស់ ព្រះអង្គឆ្វេងយល់ពីមុនមក នៅក្នុងសត-វត្សរ៍ទី២០ យើងមុខជាមានផលិតឱសថក្នុកែអ៊ីន ហេតុនេះព្រះអង្គ ហាមមិនឱ្យយើងទទួលទាននោះ ។ ឱសថស្រវឹងគឺរួម មានទាំងល្បែងអាប៉ោង ហើយអ្វីទាំងអស់ដែលធ្វើខកខូចចិត្តមនុស្សយើង ធ្វើឱ្យយើងលេងសប្បាយតាមផ្លូវកាយ ឱ្យយើងភ្លេចការស្វែងរកក់សាន្តតាមផ្លូវចិត្ត ។ បើយើងចង់ហោះហើរឱ្យបានរហ័ស ឱ្យបានខ្ពស់ដោយ

ឥតមានគ្រោះថ្នាក់ គឺសុទ្ធសឹងតែមានក្បួនច្បាប់ដូចតែក្បួនក្នុងលោកនេះ ។ បើកាលណាគេចង់បង្ហោះរ៉ុក-កែត អ្នកវិទ្យាសាស្ត្រត្រូវ ពិនិត្យក្រិត្យវិន័យតែប៉ុណ្ណេះទេ បើយើងចង់ហោះ ខ្ពស់ហោះឆ្ងាយជាងរ៉ុក-កេត ឆ្ងាយជាងយូ-រ៉េបអូនោះ គឺយើងត្រូវតែប្រុងប្រយ័ត្នដល់បែបណាទេ? នៅមានសាច់រឿងពិស្តារទៅទៀត តើលោកអ្នកចូលចិត្តស្តាប់ ទេ? នោះនៅពេលលោកអ្នកធ្វើសង្រ្គាមវិទ្យា ។ ឥឡូវនេះអាត្មាពុំចង់ឆាឆៅលោកអ្នកអំពីព្រះក្រិត្យវិន័យ " ខ្ញុំដឹងហើយ " " ខ្ញុំដឹងហើយ " ខ្ញុំមានអានក្នុងគម្ពីររួចហើយ មាន១០ខ ហាមប្រាមបទបញ្ញាទាំង១០ខ ។ ភាគច្រើនយើងមានអានក្បួនច្បាប់ទាំងនេះ តែគេមិនចាប់អារម្មណ៍ប៉ុន្មាន ហើយពុំយល់ប៉ុន្មានទេ ។ យើងចង់យល់នូវអ្វីដែលយើងធ្វើប៉ុណ្ណោះ ប៉ុន្តែពុំមែនធ្វើតាមន័យរបស់ក្បួនច្បាប់នោះទេ ។ ហេតុនោះជូនកាល គេរំលើកយើងដោយឥតមានអំពើអន្តរាយអ្វី និងស្តាប់នូវអត្ថន័យជ្រៅៗខ្លះទៀតនៃគម្ពីរអស់នោះ ។ ឧបមាថា ក្នុងគម្ពីរសម័យបុរាណទំព័រទី១ ព្រះអង្គថែងថា អាត្មាបង្កើតសត្វធាតុទាំងឡាយធ្វើជាមិត្តរបស់លោកអ្នក ហើយជួយទំនុកបំរុងមិត្ត ហើយអ្នកនឹងត្រួតត្រាពួកវា ។ រួចព្រះអង្គមានព្រះបន្ទូលថា ព្រះអង្គបង្កើតអាហារសព្វយ៉ាង បង្កើតស្មៅនៅទីវាល និងផ្លែឈើនៅគ្រប់ដើមឈើដែលមានឱជារស ហើយគួរចាប់ចិត្តផង ។ អស់ទាំងនេះជាម្ហូបអាហាររបស់អ្នក ។ ប៉ុន្តែតិចមានអ្នកណាយកចិត្តទុកដាក់ទេ មានចំ-នួនជនតាមក្បួននេះជាច្រើន នៅតែមិនយល់ព្រះអង្គមានបន្ទូលជាខ្លឹមសារអ្វីខ្លះ ។ បើសិនជាយើងសិក្សាស្រាវជ្រាវជ្រៅ បន្តិចចូលផ្នែកវិទ្យាសាស្ត្រ យើងដឹងថាយើងពុំមែនទទួលមាន ដោយឥតរើសមុខម្ហូបនោះទេ ។ ប្រព័ន្ធទាំងឡាយក្នុងខ្លួនមានដូចជាក្រពះបាយធំតូច ធ្មេញ របស់ទាំងអស់នេះសុទ្ធតែត្រូវបង្កើតឡើងជាវិទ្យាសាស្ត្រ សំរាប់ឱ្យអ្នកទទួលទានម្ហូបសាបប៉ុណ្ណោះឯង ។ ដោយយើងមិន

ប្លែកភាគច្រើន មានជម្ងឺឆាប់ចាស់ ឆាប់ហត់កាន់តែ ភ្លេចបន្តិចម្ដងៗ ចាស់កាលណាច្រើនតែ ពិបាកក្នុងខ្លួនកាលនោះ ។ ពីព្រោះយើងធ្វើឱ្យខូចខាតដល់រថយន្ត ធ្វើឱ្យខូចខាតវត្ថុយ៉ូ-អូ របស់យើងចង់ ប្រើរថយន្តឱ្យបានយូរ ហើយម៉ាស៊ីនល្អផងនោះ អ្នកត្រូវថែរក្សាថ្នាក់ថ្នម តាមរបៀបត្រឹមត្រូវ ។ ឧបមាថាយើងមានរថយន្ត យើងទាំងអស់គ្នាបើកបរឡាន បើសិនជាយើងរួមប្រេងសាំងខុសប្រភេទវា តើនឹងមានបញ្ហាអ្វីកើតឡើង? បញ្ហាអ្វីកើតឡើង យើងគ្រាន់តែបើកបរក្នុងរង្វង់ពីរបីហ្វីតមុខជាឈប់ភ្លាម ហើយយើងមិនបន្ទោសរថយន្តដែរ ដោយមកពីកំហុសរបស់យើង ព្រោះយើងចាក់ខុសប្រភេទសាំងរបស់វា ឬបើសិនជាប្រេងសាំង មានលាយទឹកក្នុងនោះ រថយន្តអាចរត់បានក្នុងមួយរយៈខ្លីតែវាទៅមានបញ្ហា ។ មែនទេ? បើសិនប្រេងក្រខ្វក់យើងមិនសំអាតបោសហោង រត់បានមួយពេលប៉ុណ្ណោះ រួចមុខជាមានបញ្ហា ហើយជូនកាលផ្ទុះ បើយើងមិនថែរក្សាវាឱ្យត្រឹមត្រូវ--- មែនទេ? ។ ដូចគ្នានឹងមនុស្សយើងអីចឹងដែររថយន្ត យើងអាចហោះហើរពីទីនេះទៅដល់ទីចុងផុតនៃអាកាសសូន្យហោះដល់គីរិតឈ្មោសវៃនៃវិទ្យាសាស្ត្រ ។ ប៉ុន្តែយើងធ្វើឱ្យវិនាស ហើយយើងមិនប្រើការវាតាមរបៀបត្រឹមត្រូវ ។ ឧបមាថា រថយន្តបញ្ជិះយើងទៅកាន់ការិយាល័យ ទៅកាន់គេហដ្ឋានមិត្តភ័ក្ត្រ និងទៅកាន់ទេសភាពល្អនានាទៀត តែយើងមិនព្រមថែទាំវា យើងចាក់ប្រេងខុសប្រភេទវា មិនមើលទឹកប្រេងក្រោយមកមុខជារត់អត់មានល្បឿនទេ ហើយមិនអាចរត់ឆ្ងាយទៀតផង យើងគ្រាន់តែរត់ជុំវិញទីធ្លារតរិលចុះរិលឡើង ។ តែប៉ុណ្ណឹងក៏បានដែរ លោកអ្នកយល់ទេ? តែថាយើងបោះបង់គោលបំណងទិញរថយន្ត បោះបង់លុយកាក់និងពេលវេលា និងថាមពលរបស់យើងឥតប្រយោជន៍ តែប៉ុណ្ណឹងទេ យើងអត់បន្ទោសដាក់កំហុសម្នាក់ណាឡើយ ភ្នាក់ងារនគរបាលក៏មិនអាចពិន័យប្រាក់អ្នកបានទេ នេះគ្រាន់តែយើងបោះបង់ចោលរថយន្តប៉ុណ្ណឹងឯង បោះបង់លុយកាក់ក្នុង

ពេលលោកអ្នកអាចធ្វើដំណើរទៅ ឆ្ងាយទៅទៀត ឬអាចទៅទស្សនាកំសាន្តនៅទីនិមួយៗក៏សឹងតែបានដែរ ។ មិនខុសអ្វីពីខ្លួនមនុស្សយើង យើងអាចរស់នៅក្នុងពិភពលោកនេះ ដោយយើងត្រូវ ថែរក្សាខ្លួនយើង និងគ្រឿងឧបករណ៍ដទៃទៀត នោះទើបយើងអាចហោះហើរផុតពីនោះបាន ។ មិនខុសអ្វីអ្នកបើកបរក្នុងអាកាសគេជិះលើ រ៉ុក-កែត រ៉ុកកែត ជាគ្រឿងឧបករណ៍ ។ គេត្រូវថែទាំត្រឹមត្រូវ ទើបវាអាចហោះហើរបានសុខសាន្ត ហើយរហ័សទៀតផង ។ រ៉ុក-កែត នាំចេញគេទៅដល់ទីកន្លែងចុះចតតែរ៉ុក-កែត ពុំមែនជាវត្ថុធំចម្បងនោះទេ គឺមានតែមនុស្ស ហើយកន្លែងចុះចតទើបសំខាន់ ។ ហើយគេគ្រាន់តែជិះវាព័ទ្ធជុំវិញ ឡុងអៃឡឺន ប៉ុណ្ណោះ បាត់បង់ពេលវេលា លោកអ្នកយល់ទេ? ខាតបង់លុយកាក់របស់រដ្ឋតែប៉ុណ្ណោះ ។ ហេតុនេះ ខ្លួនយើងពិតជាពិសេសវិសាលណាស់ ព្រោះព្រះគ្រូគង់នៅក្នុងខ្លួនអ្នកនោះ ដូច្នោះបានជាក្នុងគម្ពីរចែងថា : លោកអ្នកមិនដឹងទេ ក្នុងខ្លួនអ្នកនេះឯង ដែលជាព្រះវិហាររបស់ព្រះជាម្ចាស់ ហើយព្រះបរមគ្រូឋិតនៅក្នុងខ្លួនអ្នកតែម្តង ។ បើយើងយកអារក្សអ្នកតា ឬព្រះទេព្តាធ្វើសក្ការៈបូជា លោកអ្នកអាចស្មានបានទេនូវភាពសំខាន់យ៉ាងអស្ចារ្យនោះ ។ ប៉ុន្តែមនុស្ស យើងភាគច្រើនអានរហ័សពេក តែមិនយល់ មិនស្គាល់ ទំហំអត្ថន័យរបស់ឃ្លាទាំងនេះ ហើយគេមិនខិតខំរករកអត្ថន័យ ។ ហេតុនេះបានជា កូនសិស្សអាត្មាចូលចិត្តធ្វើតាមការបង្រៀនប្រដៅរបស់អាត្មាពីព្រោះពួកគេ រកឃើញអ្នកណានៅក្នុងខ្លួន ហើយអ្វីមាននៅលើលោកនេះ ដោយឡែកអំពីការខំប្រឹង ប្រែងប្រឈមមុខ នឹងការរកលុយកាក់រៀងរាល់ថ្ងៃ ការខំចាប់អារម្មណ៍ខ្លាំង និងបញ្ហាជីវិតនៅរស់ទាំងអស់នេះ ។ យើងមានសោភ័ណភាពច្រើន-សេរីភាពច្រើន និងចំណេះដឹងក្នុងខ្លួនច្រើន ។ យើងស្គាល់វិធីត្រឹមត្រូវ ដើម្បីទាក់ទងនេះ គឺជាភារកិច្ចរបស់យើង ព្រោះយើងមានអ្វីៗទាំងអស់ក្នុងខ្លួន ។ គ្រាន់តែយើងមិនដឹងតើ គន្លឹះនៅទីណា

ហើយយើងបិទទ្វារផ្ទះចោលជាយូរ ណាស់មកហើយ តែឥឡូវនេះយេងភ្លេចថា យើងមាន ភោគសម្បត្តិច្រើនបែបនេះសោះ ។ មានតែទាំងអស់ហ្នឹង ។ ហេតុនេះព្រះគ្រូជាអ្នកជួយបើកទ្វារ ហើយបង្ហាញយើងនូវ អ្វីដែលជាកម្មសិទ្ធិ របស់យើងរួចមកហើយ តែយើងត្រូវធ្វើសិទ្ធិម៉ែម១ឈានចូលចិត្តហើយ ពិនិត្យអ្វីៗ ទាំងនោះ ។ យ៉ាងណាក៏ដោយ យើងនៅក្នុងឋានទី២ទៅហើយ ។ លោកអ្នកចូលចិត្តធ្វើដំណើរ ទៅឆ្ងាយថែមទៀតទេ ចាំ ! ចាំ ! ទស្សនៈជនឆ្លង ឆ្លើយ លោកអ្នកចង់ស្គាល់អ្វីទាំងរស់ដោយពុំមានចង់ធ្វើការ ឬយ៉ាងម្តេច? (ព្រះគ្រូសើច)អញ្ចឹងបានហើយ។ ប៉ុន្តែយ៉ាងហោចណាស់ ក៏មានអ្នកណាម្នាក់ អាចនិយាយប្រាប់អ្នកថា តើប្រទេសដទៃបែបណាទៅ នៅពេលគេបានទៅដល់ ទីនោះ អ្នកពុំបានទៅដល់នោះទេ មែនអញ្ចឹងទេ? យ៉ាងហោចណាស់អ្នកចង់ ទៅដែរ ។ ឥឡូវនេះ ក្រោយពីឋានទី២ អាត្មាពុំទាន់បញ្ចប់នូវឋាន ទី២ឡើយ តែលោកអ្នកដឹងថាយើងមិនអាចអង្គុយពេញ មួយថ្ងៃនៅទីនេះបានឡើយ ។ ហេតុនេះ ក្រោយពីឋាន ទី២មក លោកអ្នកមុខជាមានវិទ្ធអំណាចថែមទៀត បើ សិនជាលោកធ្វើការម៉ឺងម៉ាត់ មុខជាលោកអ្នកធ្វើដំណើរ ឡើងទៅឋានទី៣ ជាមិនខាន ។ នៅអ្វីដែលគេ ហៅថាឋានទី3នោះ គឺមានជំហានមួយខ្ពស់ទៀត ផង ។ យ៉ាងហោចណាស់ អ្នកណាម្នាក់ឡើងទៅឋានទី៣ គឺត្រូវស្អាតស្អំ ជំរះអស់បំណុលក្នុងលោកនេះ លោកអ្នកយល់ទេ? បើយើងជំពាក់បំណុល ព្រះរាជាក្នុងលោកនេះ យើងពិតជាមិនអាចឡើងបានទេ បើលោកអ្នកមាន ទោសចោទឡើង ក្នុងប្រទេសណាមួយ អ្នករត់បានគេអនុញ្ញាតិលុបលៀង ទោសកំហុសក្នុងសំណុំរឿងនោះ អ្នកមិនអាចឆ្លងដែនទៅរស់នៅប្រទេសមួយ ណាផ្សេងបានឡើយ ។ បំណុលគឺអ្វីដែលយើងធ្វើទុកមកក្នុងអតីតកាល ក្នុងបច្ចុប្បន្ន ហើយក៏អាចនៅក្នុងអនាគតនៃជាតិនេះផង ។ យើងត្រូវជំរះនូវអ្វី ទាំងអស់នោះ ជំរះនូវទម្លាប់ប្រពៃណីរបស់យើងមុននឹងទៅកាន់ឋានខាងម្ខាង

នោះ ។ បើយើងនៅក្នុងឋានទី២ យើងត្រូវទៅធ្វើការ លោកអ្នក យល់មិនអាចលះលាកម្មពៀរពីជាតិមុន និងជាតិនេះទេ ។ ពីព្រោះបើឥតមានកម្មពៀរក្នុងអតីតកាល យើងមិនអាចនៅរស់ក្នុងបច្ចុប្បន្ននេះបានទេ ។

ព្រះគ្រូមានពីរជំពូកខុសគ្នា ។ មួយឥតមានជាប់កម្មពៀរ តែគេខ្ចីកម្មនេះដើម្បីចុះទៅឋានក្រោមមួយទៀត ដូចជាយើងជាមនុស្សសាមញ្ញតែស្អាតស្អំ ។ ហេតុនេះនរណាក៏ដោយក៏អាចទៅជាព្រះគ្រូអាចារ្យ ក្នុងអនាគត ហើយជួនកាលព្រះគ្រូអាចារ្យចយុត្រចុះ មកទីនេះដោយជំពាក់កម្មជាមួយផង ។ (ព្រះគ្រូសើច) អាចដូច្នោះមែន អាចដូច្នោះមែន! ឧបមាថាលោកអ្នកចុះមកទីនេះដោយសារពីជាតិមុន អ្នកបានមកទៅទីនេះ រួចហើយ ចាំ! អ្នកបានចាប់កំណើត ហើយស្លាប់ទៅ វិញជាច្រើនជំនាន់ រួចលោកអ្នកត្រឡប់ទៅឋានសួគ៌ ឬទីកន្លែងរបស់អ្នកនៅឆ្ងាយពីនេះ នៅគីរិតខុសគ្នា យ៉ាងហោចណាស់នៅគីរិតទី៥ ។ ផ្ទះរបស់ព្រះគ្រូគឺ ឋានទី៤ ។ ក្រៅពីនោះនៅមានគីរិតច្រើនទៀត ។ យើងត្រឡប់មកកាន់លោកនេះ ដោយមកពីយើងមានមេត្តាធម៌ ឬមួយព្រះបិតានៃយើងបានចាត់តាក់តែងឱ្យយើង ហើយដោយមកពីយើងមានភ័ព្វវាសនានឹងជនទាំងឡាយក្នុងអតីតកាល បានជាយើងខ្ចីកម្មរបស់ គេមកតាមឥតមានអ្វីល្អនោះទេ មនុស្សយើងមានតែ បំណុលប៉ុណ្ណោះឯង ។ យើងអាចខ្ចីបុលគេ រួចសងទៅវិញ លោកអ្នកយល់ទេ? ទំរាំតែយើងសំរេចកិច្ចការក្នុងលោកនេះ ។ ហេតុនេះមានច្រើនជំពូក ។ គ្រូអាចារ្យ-ចាំ! ហើយក៏គង់មានអ្នកខ្លះគេកើតមកក្នុងលោកនេះ ក្រោយពីប្រតិបត្តិមក គេបានទៅជាព្រះអាចារ្យនៅទីនេះ មិនខុសអ្វីគេរៀនចប់ចេញពីសាលា ។ ចាំ! ដូចជានៅមហាវិទ្យាល័យ យើងមានសាស្ត្រាចារ្យ មាននិសិត្ស គេចេញពីសាលាហើយទៅជាសាស្ត្រាចារ្យក្រោយមក ។ លោកអ្នកយល់ទេ មានសាស្ត្រាចារ្យបង្ហាត់បង្រៀនជាយូរមក ហើយនិងសាស្ត្រាចារ្យថ្មីជាដើម --- មិនខុសគ្នានឹង

គ្រូអាចារ្យជំពូកអស់ទាំងនេះដែរ ។ បើយើងចង់ឡើងទៅពិភពលោកទី៣ យើង ត្រូវជំរះឱ្យអស់នូវកម្មពៀរ ។ កម្មា គឺជាក្បួនច្បាប់ម្យ៉ាង អ្នកសាបព្រួសពូជណា អ្នកមុខជាច្រូតកាត់លទ្ធផលនោះ ដូចជាយើងដាំក្រូច រួចយើងបេះផ្លែក្រូច យើងដាំបោម យើងបេះផ្លែបោម នោះហើយគេហៅថាកម្មា ។ នេះជាពាក្យសំស្ក្រឹត គឺថាបុព្វហេតុ ឬចងកម្មពៀរនឹងគ្នា ។ ក្នុងគម្ពីរពុំចែង អំពីកម្មា គ្រាន់តែថាៈ ដោយសារអ្នកព្រួស អ្នកមុខជានឹងច្រូតកាត់មិនខាន ។ ដូចតែគ្នាក្នុងន័យនោះដែរ ។ គម្ពីរជាក្បួនមួយបែបបង្រៀនប្រដៅដោយ សង្ខេបរបស់គ្រូអាចារ្យ ហើយយ៉ាងណាមិញ អាយុជីវិតរបស់គ្រូអាចារ្យក៏ខ្លី ដូច្នោះដែរ ។ ដូច្នោះ យើងមិនចាំបាច់អធិប្បាយអ្វីច្រើនក្នុងគម្ពីរនោះមានប្រ- យោគ ក្នុងគម្ពីរជាច្រើនត្រូវគេលុបចោល ដើម្បីឱ្យសមទៅតាមបំណងរបស់ អស់លោកមេដឹកនាំសហគមន៍ក្នុងជំនាន់នោះ ។ លោកអ្នកជ្រាបថា នៅគ្រប់ វិស័យមនុស្សយើងលក់ និងទិញគ្រប់ចុន ។ ឈ្មួញលក់ដូរ មាននៅ គ្រប់វិស័យទាំងអស់ ប៉ុន្តែក្នុងគម្ពីរ គម្ពីរត្រឹមត្រូវ យើងដឹងថា ក្នុងគម្ពីរមានប្រយោគខុសពី ក្បាលទិចបន្តិច ហើយមានប្រយោគខ្លះវែងជាងនោះ ច្បាស់ជាង ហើយងាយយល់ជាង ។ យ៉ាងណាមិញ ព្រោះយើងមិនអាច បង្ហាញសាក្សីឱ្យបានច្រើនមកពី យើងមិននិយាយអំពីរឿងនេះ ខ្លាចក្រែងមានគេ ឯងនិយាយថា យើងនិយាយបង្អាប់បន្ទោសលើព្រះធម៌ទៅវិញ ។ ហេតុដូច្នេះ យើងអាចនិយាយអ្វីមួយ ដែលយើងអាចបង្ហាញឱ្យគេឃើញ ។ លោកអ្នកមុខ ជា សួរអាត្មាថាៈ "ព្រះគ្រូអាចារ្យ និទានអំពីពិភពលោកទី២ ពិភពលោកទី៣-- ទី៤ ។ តើព្រះគ្រូអាចបង្ហាញឱ្យគេឃើញបានឬទេ? អាត្មាអាច បង្ហាញ អាត្មាអាចបង្ហាញរឿងនេះ យល់ទេ? ប៉ុន្តែបើលោកអ្នកមិនជឿទេ អាត្មា អាចបង្ហាញឱ្យអ្នកបានឡើយ ។ ពិតដូច្នោះ --- ពិតដូច្នោះមែន អាត្មា

និយាយរឿងអស់នេះដោយសារ មានសាក្សី ។ យើងដោយយើងមានចំនួនរាប់រយកូនសិស្សនៅជុំវិញពិភពលោក ។ ដូច្នោះ យើងមិនអាចនិយាយអ្វីដែលយើងដឹង ។ ឧបមាថា បើលោកអ្នក ចង់ដើរទៅកាន់ --- តែលោកអ្នកត្រូវដើរជាមួយអាត្មា អ្នកត្រូវដើរ បើមិនអញ្ចឹងអ្នកមិនអាចនិយាយបានឡើយ "វ៉ាវ! អ្នកដើរឱ្យអាត្មា ហើយនិយាយប្រាប់អាត្មា ហើយបង្ហាញប្រាប់អាត្មាអ្វីៗទាំងអស់" អាត្មាមិនអាចធ្វើបែបនេះ ។ ឧបមាអាត្មាមិននិមន្តមកទីស្នងការអង្គការសហប្រជាជាតិនៅក្នុងបន្ទប់នេះ តើលោកអ្នកអាចនិយាយ អំពីបន្ទប់នេះដូចម្តេចទៅ? អាត្មាពុំបានដឹងច្បាស់នៅឡើយ ។ មែនចឹងទេ? ហេតុនេះយើងត្រូវតែដើរតាមអ្នកណាម្នាក់ ដែលមានការពិសោធន៍ដឹកនាំ យើងអាត្មាមានកូនសិស្សខ្លះៗ នៅក្នុងបន្ទប់នេះ ដែលមានសញ្ជាតិខុសៗគ្នា គេមានលទ្ធផលពិសោធន៍នេះ អាត្មា ទើបតែជំរាបលោកអ្នកអម្បាញមិញនេះ ដោយមានជាភាគ ឬមានទាំងស្រុង ។ ចាំ ! ចាំ ! ក្រោយពីពិភពលោកទី៣ គឺឥតមានអ្វីទាំងអស់ ។ អ្វីដែល អាត្មាជំរាបជូនគ្រាន់តែមួយភាគប៉ុណ្ណោះនៅត្រង់ជំពូកធ្វើដំណើរ មានទាក់ទិនរឿងក្នុងភាគមួយតូចមិនរ៉ាយរាប់ ៣០ ពិស្តារទេ ។ ទោះថាយើងអានសៀវភៅ ក្បួនតម្រីរបស់ប្រទេសមួយចំនួននោះ ក៏ពុំមែនជាប្រទេសពិតៗទេ មែនអញ្ចឹងមេ? ហេតុនេះយើងមានសៀវភៅក្រាំងតម្ពីរស្តីអំពីការធ្វើដំណើរ ស្តីអំពីប្រទេសខ្លះៗនៅលើពិភពលោក តែយើងនៅតែចង់ទៅផ្ទាល់ខ្លួន ។ មែនចឹងទេ?យើងស្គាល់ប្រទេសអែស្បាញ៉ុល តេណេរីប និងប្រទេសព្រែក ប៉ុន្តែនៅទីនោះមានតែខ្សែភាពយន្ត និងសៀវភៅប៉ុណ្ណោះ ។ យើងត្រូវទៅដល់ទីនោះ ហើយយើងច្បាស់ជាស្គាល់នូវភាពរីករាយ កំសាន្ត ហើយយើងក៏ស្គាល់នូវមុខម្ហូបអាហារ តេបំរើយើងព្រមឆ្នេរសមុទ្រ និងផ្ទៃទឹក ធាតុអាកាស មនុស្សម្នាជាមេត្រីភាព បរិយាកាសគ្រប់ជំពូកដែលយើង មិនអាចស្គាល់អស់នោះ ដោយគ្រាន់តែអានសៀវភៅប៉ុណ្ណោះ ។ ឧបមាយ៉ាងណាក៏ដោយ លោកអ្នកបាន

កាត់ ឆ្លងពិភពលោកទី៣រួចហើយ តើអ្វីនៅពិភពលោកខ្ពស់ជាងនេះបន្តិច គឺពិភពលោកទី៤នោះ ។ គឺពិភពលោកទី៤ ពិតជាឋានមួយដ៏អស្ចារ្យ យើងមិនអាចប្រើពាក្យ ពិពណ៌នាមនុស្សលោកខ្លាចមានទោសកំហុសរវាងព្រះជាម្ចាស់នៅពិភពលោកនោះ ។ ពីព្រោះពិភពលោកនោះល្អយ៉ាងប្រណិត ថ្វីបើមានភាពខ្លះងងឹតឈឹង ងងឹតជាងគេផ្តាច់ចង្កៀងអគ្គិសនីនៅក្រុងញ៉ូវ-យ៉កទៅទៀត ។ លោកអ្នកដែលមានពិសោធន៍អំពីទីក្រុង ភាពងងឹតឈឹងទាំងស្រុងទេ? ចំ : ! ងងឹតជាងនោះទៅទៀត ។ ប៉ុន្តែមុនលោកអ្នកទៅដល់ទីកន្លែងភ្លឺពិត ជាងងឹតជាងនោះទៅទៀត ។ នោះជាទីក្រុងត្រូវហាម មិនឱ្យចេញចូល ។ មុននឹងយើងជួបប្រទះបញ្ហានៃ ទេព្ត យើងត្រូវឈប់សំរាកនៅទីនោះ ។ ប៉ុន្តែដោយមានព្រះគ្រូអាចារ្យទៅតាមគ្រូអាចារ្យមានការពិ-សោធន៍ អ្នកអាចឆ្លងកាត់បានទេ ពុំនោះទេយើងមិនអាចរកផ្លូវដើរនៅក្នុងពិភពលោកនោះបានទេ ។ កាលបើយើងទៅដល់ឋានទាំងនោះ យើងមានការពិសោធន៍ពីមុនមក គឺមិនត្រឹមតែស្មារតីយើងផ្លាស់ប្តូរ ប៉ុន្តែផ្លូវកាយវិញក៏ផ្លាស់ប្តូរដែរ ផ្លាស់ប្តូរបញ្ញា ផ្លាស់ប្តូរអ្វីៗទាំង-អស់ក្នុងឆាកជីវិត ។ យើងសម្លឹងមើលជីវិតមនុស្ស ខុសពីគ្នា យើងដើរខុសគ្នា យើងធ្វើការខុសៗគ្នា ។ ទោះបីការងារយើង ការងារប្រចាំថ្ងៃរបស់យើងខុសគ្នា ហើយយើងយល់ថាហេតុអ្វីយើងធ្វើការងារនេះ ហេតុអ្វីយើងនៅធ្វើការនេះ ឬហេតុអ្វី យើងគួរតែផ្លាស់ ការងារអ្វីនោះ ។ យើងយល់អំពី គោលបំណងនៃ ជីវភាពយើង យើងឥតឈប់សំរាក និងឆាឆៅទៀតទេ ចំ : ! ប៉ុន្តែយើងរង់ចាំអស់ពីចិត្តអំពី ភារៈកិច្ចរបស់យើងត្រូវបំពេញ ព្រោះយើងដឹងយើងត្រូវទៅមុខទៀត ។ យើងដឹងក្នុងពេលដែលយើងកំពុងរស់នៅ ។ ហេតុនោះបានជាគេថា "ស្លាប់ ក្នុងពេលរស់"

ចំ :! ចំ :! ឧបមាថា លោកអ្នកមួយ ចំនួនបានឮអំពីរឿងនេះពី មុន១ តែរាគ្នាមិនដឹង តើឱ្យគ្រូអាចារ្យអាចនិយាយ រឿងផ្សេងវិញទេ (គ្រូអាចារ្យ

សើច) មានតែយើងត្រូវ ដកពិសោធន៍ សេចក្តីរីករាយសប្បាយក្នុងខ្លួនយើងប៉ុណ្ណោះ ។ តើមានអ្នកណាមួយ អាចពណ៌នាបានទេ? អាត្មាចង់និយាយអំពីរថយន្ត ម៉ៀកស៊ីដែស-បែង្សរ៍ ដោយខុសពីគ្នានោះមែនអញ្ចឹង ទេ? នោះដូចតែគ្នាទេ។ ហេតុនោះនរណាម្នាក់ មានរថយន្តម៉ៀកស៊ីដែស មុខតែគេស្គាល់បែង្សរ៍ គេពណ៌នាមិនខុសគ្នាទេ ប៉ុន្តែនោះមិនមែនជា ប៉ែង្សរ៍ទេ ។ ថ្វីបើអាត្មានិយាយលោកអ្នក ដោយប្រើពាក្យសាមញ្ញតែអ្វីៗ ដែលយើងបានឃើញពុំមែនជាធម្មតាទេ គឺយើងត្រូវធ្វើការដកពិសោធន៍ខ្លួន យើងផ្ទាល់ដោយធ្វើការដោយចិត្តជ្រះថ្លា ហើយនិងមានការដឹកនាំវិធីនេះ ទើបឃើញថាស្រួលជាង ។ ទោះបីអាចកើតឡើងក្តី មានតែមួយគត់ ក្នុងចំនួនមួយលានដែលអាចធ្វើផ្ទាល់ ខ្លួនយើងដោយគ្រោះថ្នាក់ ហើយមិនសំរេចលទ្ធផលដូចបំណងឡើយ ។ មានមនុស្សមួយចំនួនដូចជា ស៊ីរតដែនបរ៍ គេមានវិធីអនុវត្តន៍ដោយខ្លួនឯង ឬក៏ដូចជាតូតសែបអនុវត្តន៍វិធីនេះដោយ ខ្លួនឯងហើយគេអាចអនុវត្តន៍ដោយខ្លួនម្នាក់ឯង ។ ប៉ុន្តែអាត្មាឃើញមានមនុស្សមួយចំនួនអនុវត្តន៍វិធីនេះប្រកបនូវគ្រោះថ្នាក់ ហើយនិងឧបសគ្គជាមិនខាន ។ ហើយពុំមែនថា ជាវិធីសំខាន់ដែលអាចឡើងទៅកាន់ឋានខ្ពស់បំផុតនោះក៏ទេដែរ ។ ហេតុនោះក្រោយពី យើងដើរទៅកាន់ ឋានខ្ពស់ជាងនេះ ក្រោយពីឋានទី៨ អ្នកឡើងទៅកាន់ឋានខ្ពស់ជាងនេះទៀត ។ គេហៅឋានរបស់ព្រះគ្រូគឺ ឋានទី៩ គ្រូអាចារ្យទាំងអស់សុទ្ធតែមក ពីឋាននេះ ។ ទោះបីជាឋានរបស់គ្រូអាចារ្យទាំងនោះ ខ្ពស់ជាងឋាន ទី៩ ប៉ុន្តែត្រូវតែគង់នៅទីនោះ ពីព្រោះ គឺជាឋានរបស់ព្រះគ្រូ ហើយផុតពីនោះ គឺមានទីឋានជាច្រើនរបស់ ទេវរាជពិបាកយល់ណាស់ ។ អាត្មាខ្លាច ធ្វើឱ្យលោក អ្នកច្របូកច្របល់ ទុកពេលក្រោយអាត្មា ពន្យល់ប្រាប់ ឬមួយទុកពេលក្រោយពី លោកអ្នកបាន ទទួលសច្ចាប្រណិធានជាកូនសិស្ស ពេលនោះលោកអ្នកមានការរៀបចំត្រឹមត្រូវរួច អាត្មាជំរាបប្រាប់អំពីអ្វីៗដ៏

អស្ចារ្យតាមការនឹកស្មានរបស់លោកអ្នកឱ្យឃើញការខ្វែងគំនិតគ្នាអំពី ទេវរាជ ។ បើមានសំណួរណាមួយ អាត្មាសូមស្វាគមន៍ ហើយលោកអ្នកនឹងត្រូវបានស្វាគមន៍ទៀត ដោយបេក្រវែងអាត្មាចេញពីនេះ បើសិនជាមិនឱ្យលោកអ្នកសប្បាយចិត្តនោះ (ព្រះគ្រូអាចារ្យ សើច) អាត្មាដើរចេញដោយរីករាយ ។ មានសំណួរអ្វីទេ? សូមអញ្ជើញ ចំ :! ចំ :! សូមរង់ចាំអញ្ចឹង ក៏បានដែរ! មិនថ្វីទេ! ទេ! ទេ! សូមរង់ចាំឧបល្លោសទសព្ទ តេអាចឮលោកអ្នកនិយាយអ្វី ។

សំណួរ: ព្រះគ្រូមានពុទ្ធដីកាថា ព្រះគ្រូខ្ចីយក កម្មពីមនុស្សសត្វ ។ បើដូច្នោះពៀរមនុស្សនោះ ត្រូវជំរះអស់? តើមានផលវិបត្តិអ្វីដល់អ្នករស់នោះ?

ព្រះគ្រូ : ចំ :! ចំ :! ឱ! ព្រះគ្រូអាចជំរះ កម្មារបស់មនុស្សសត្វទាំងអស់នោះបើសិនជាព្រះគ្រូជ្រើសរើសធ្វើ ។ តាមពិតទៅកូនសិស្សទាំង-ឡាយត្រូវបានជំរះអស់កម្មាពៀរ នៅពេលទទួលសច្ចាប្រណិធាន ជាកូនសិស្សនោះកម្មពៀរក្នុងអតីតកាលត្រូវជំរះអស់ អាត្មាទុកឱ្យអ្នកមានកម្មពៀរក្នុងបច្ចុប្បន្នហើយបន្តការរស់នៅក្នុងជាតិនេះ បើមិនអីចឹងយើងស្លាប់ភ្លាម ។ បើឥតមានកម្មមិនអាចរស់បាននៅទីនេះទេ ។ ហេតុនេះបានជាអាត្មាជំរះអស់កម្មពៀរដើម្បីឱ្យជន នោះស្អាតស្អំ ហើយទុកឱ្យគេជាប់កម្មបន្តិចបន្តួច បន្តការរស់នៅនិងធ្វើអ្វីដែលត្រូវធ្វើក្នុងជាតិនេះ ។ ក្រោយពីនេះគឺសំរេចវិ ។ ហេតុនេះយើងអាចទៅរបៀបណេក? ទោះបីគេស្អាតស្អំបែបណា? តើជាតិ មុនយ៉ាងណា? ចំ :! ចំ :!

សំណួរ : សូមអរគុណ ។

ព្រះគ្រូអាចារ្យ : អាត្មាសូមស្វាគមន៍លោក អ្នកសំណួរទាំងនេះល្អប្រពៃណាស់ ។ អាត្មាយល់ថា លោកអ្នកយកចិតទុកដាក់ទៅហើយ-មានសំណួរអ្វីទៀតទេ សូមអញ្ជើញ ។

ព្រះគ្រូ : គោលគំនិតអ្វី? អាត្មាមិនដឹងរាប លោកអ្នកឬ? ដើរផុតពីលោកនេះត្រឡប់ចូលស្ថានទេវរាជ ស្គាល់នូវភាពឈ្លាសវៃ ហើយធ្វើជាមនុស្សម្នាក់ ត្រឹមត្រូវក្នុងជាតិនេះ ។

សំណួរ : តើមានកម្មានៅគ្រប់ឋានទេ?

ព្រះគ្រូ : ហ៊ឹម! ពុំមាននៅគ្រប់ឋានទាំងអស់នោះទេ មានត្រឹមតែឋានទី២ប៉ុណ្ណោះ ។ ពីព្រោះខួរក្បាលយើង ម៉ាស៊ីនកំព្យូទ័រផលិតឡើងនៅឋានទី២ ។ កាលបើយើងដើរចុះមកពីជាន់ខ្ពស់មកជាន់មានរូបរាងចុះមកធ្វើការ អញ្ចឹងមែន? ទោះថាគ្រូអាចារ្យចុះមក ពីឋានទី៥ មកលោកនេះ ព្រះអង្គត្រូវដើរចុះឋានទី២ ហើយយកម៉ាស៊ីនកំព្យូទ័រ ដើម្បីយកមកប្រើការក្នុងលោកនេះ ។ មិនខុសអ្វីអ្នកមុជទឹក គេមុជចុះទៅក្នុងសមុទ្រ គេត្រូវរៀបចំប្រដាប់ពាក់មុខខ្យល់ អ៊ុកស៊ីសែ្សនអ្វីៗទាំងអស់ ។ ទោះបីខ្លួនគេពុំមានអ្វីគួរឱ្យអស់សំណើចនោះទេ តែបើពាក់មុខ ពាក់សំលៀកបំពាក់ អ្នកមុជទឹកពាក់បំពង់អ៊ុកស៊ីសែ្សន យើងឃើញដូចជា កង្កែបអញ្ចឹង ។ ដូច្នេះតើយើងមានពេលពាក់ម៉ាស៊ីន កំព្យូទ័រចូលឃើញប្លែកវិញ បើដូច្នេះទេមនុស្សយើងសមរម្យណាស់ ។ ទោះបីលោកអ្នកយល់ឃើញថា ខ្លួនស្អាតល្អក្នុងពេលនេះ តែបើប្រៀបនិងការពិតទៅវិញ អ្នកអាក្រក់ណាស់វិញទេ អ្នកយល់ទេ? ពីព្រោះគ្រឿងឧបករណ៍ទាំងឡាយយើងបំពាក់នោះ គឺសំរាប់មុជចុះក្នុងលោកនេះដើម្បីធ្វើការប៉ុណ្ណោះ ។ ក្រោយពីយើងឆ្លងពីឋានទី២ រួចតំរង់ទៅឋានខាងលើទៀត យើងត្រូវទុកចោលប្រដាប់អស់នេះ ដោយសារយើង មិនត្រូវការប្រើវានៅទីនោះទៀតទេ ។ មិនខុសអ្វីអ្នកមុជទឹកឡើងមកដល់ច្រាំងហើយ គេចោលបំពង់អ៊ុកស៊ី និងប្រដាប់ទាំងឡាយសំរាប់មុជនោះអស់ទៅនៅតែខ្លួនទទេ ដូចដើមវិញ ។ នេះ - នេះ - យើងមានតែឧត្បោសនស័ព្ទមួយប៉ុណ្ណោះ - ក្រណាស់ ។

សំណួរ : សូមអរគុណព្រះគ្រូអាចារ្យ សូមអរគុណ ។

ព្រះគ្រូមានបន្ទូលថា នៅទីបំផុតនៃ ឋានទី២នោះ មុននឹងឡើងទៅមុខទៀត ហើយព្រះអង្គទុកកម្មាវិញ តើព្រះអង្គត្រូវដោះស្រាយ ឬមួយជំរះ ឱ្យអស់កម្ម ពៀរនោះ ។ នោះមានន័យថា កម្មាទាំងឡាយក្នុងជាតិមុន មកដល់ជាតិនេះ ទៀត ។

